# ព្រឹត្តិបត្រ

# កម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខ ៤ | ឆ្នាំ ២០១៧



# បុព្វកថា

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ត្រូវបានរៀបចំឡើងតាមអភិក្រមជាខឿន (Platform Approach) និងអនុវត្តជាដំណាក់កាលៗ (Stage)។ ក្នុងដំណាក់កាលនីមួយៗនៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្ពុជាខិតខំកសាងខឿនមួយក្នុងចំណោមខឿនទាំងបួន ស្របពេលនឹងត្រៀមខ្លួនសម្រាប់កសាងខឿនបន្ទាប់ ហើយទន្ទឹមនឹងជំរុញវឌ្ឍនភាពនៃខឿនដែលសម្រេចបានកន្លងមក។ បច្ចុប្បន្ននេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា កំពុងស្ថិតនៅក្នុងដំណាក់កាលទី៣ “**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**” បន្ទាប់ពីឆ្លងផុតដំណាក់កាលទី១ “ភាពជឿទុកចិត្តបាននៃថវិកា” និងដំណាក់កាលទី២ “**គណនេយ្យភាពហិរញ្ញវត្ថុ**”។ ដំណាក់កាលចុងក្រោយនឹងផ្ដោតទៅលើ “**គណនេយ្យភាពចំពោះសមិទ្ធកម្ម**” សំដៅសម្រេចឱ្យបានប្រព័ន្ធថវិកាផ្អែកលើព័ត៌មានសមិទ្ធកម្មនៅឆ្នាំ២០២៥។

ក្នុងរយៈកាល ១៣ ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានសមិទ្ធផលជាច្រើន ហើយក៏ជួបប្រទះនឹងបញ្ហាប្រឈមច្រើនផងដែរ ទន្ទឹមនឹងមានសកម្មភាពមួយចំនួន មានវឌ្ឍនភាពយឺត។ ខ្ញុំសង្កេតឃើញ និងចាប់អារម្មណ៍ថា ប៉ុន្មានឆ្នាំចុងក្រោយនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានរុញច្រានទៅមុខក្នុងល្បឿនថ្មីៗ និងស្វាហាប់ជាងមុន។ ទោះជាយ៉ាងណាក៏ដោយ ភាពប្រឈមដ៏សំខាន់របស់កម្ពុជានាពេលនេះ គឺការធានាបន្តវឌ្ឍនភាពនៃការងារនេះឱ្យមានសន្ទុះទៅមុខ និងបង្កើតបានជាវប្បធម៌ស្ថាប័នមួយរឹងមាំ។ នៅក្នុងដំណាក់កាលទី៣ “**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**” នេះ រាជរដ្ឋាភិបាលបានសាកល្បងដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ ដែលបានបើកលទ្ធភាពឱ្យមន្ត្រីសាធារណៈ ធ្វើសកម្មភាពកាន់តែសកម្ម កាន់តែម្ចាស់ការ និងកាន់តែទទួលខុសត្រូវជាងមុន។ ការរៀបចំថវិកាតាមកម្មវិធី បានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចធ្វើការវិភាជធនធានមានកម្រិតរបស់ខ្លួន តម្រង់ឆ្ពោះទៅអាទិភាពគោលនយោបាយសំខាន់ៗ ស្របទៅតាមកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការអភិវឌ្ឍធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ។ល។ ម៉្យាងវិញទៀត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏សម្រេចបានជោគជ័យល្អប្រសើរផងដែរក្នុងការកៀរគរធនធានក្នុងស្រុក ដែលបានឆ្លុះបញ្ចាំងយ៉ាងច្បាស់តាមរយៈកំណើននៃចំណូលពន្ធ និងចំណូលមិនមែនពន្ធក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

ការសម្រេចបាននានាក្នុងក្របខណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់គ្រប់តួអង្គពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយនឹងយន្តការការងារច្បាស់លាស់។ លើសពីនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ដែលជាសេនាធិការក្នុងការសម្របសម្រួលរៀបចំ និងតាមដានការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រប់ក្រសួង-ស្ថាប័ន បានស្វះស្វែង ខិតខំប្រមូលចងក្រង និងផ្សព្វផ្សាយក្នុងគោលដៅលើកកម្ពស់ និងបញ្ជ្រាបការយល់ដឹងអំពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈមធ្យោបាយនានាក្នុងស្មារតីនវានុវត្តន៍ និងការទទួលខុសត្រូវខ្ពស់ ក្នុងនោះរួមមានព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានរៀបចំ និងបោះផ្សាយជាបន្តបន្ទាប់។ ខ្ញុំពិតជាមានមោទនភាព លើវឌ្ឍនភាពនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការចូលរួម ឆន្ទៈមោះមុត ស្មារតីទទួលខុសត្រូវ បុរេសកម្ម-អន្តរសកម្ម-សកម្ម របស់គ្រប់ក្រសួង-ស្ថាប័ន។ ខ្ញុំជឿជាក់ផងដែរថា ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងចូលរួមចំណែកបន្ថែមជាឧបករណ៍មួយសំខាន់ផងដែរក្នុងការចែករំលែកនូវព័ត៌មាន និងចំណេះដឹងពាក់ព័ន្ធនានាសម្រាប់ជាប្រយោជន៍ជូនមន្ត្រីរាជការ សិស្ស-និស្សិត សម្រាប់សិក្សាឈ្វេងយល់បន្ថែម។

មុននឹងបញ្ចប់ ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខ្ញុំសូមសម្ដែងកតញ្ញូកតវេទិតាធម៌ដោយគារវកិច្ចយ៉ាងវិសុទ្ធ ជូនចំពោះអគ្គមហាបុរសនៃយើង គឺ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែផ្ដល់ចក្ខុវិស័យដឹកនាំដ៏ប្រាកដនិយម និងស្ថាបនាមាគ៌ានយោបាយដ៏ត្រឹមត្រូវ ដើម្បីសម្រេចជោគជ័យលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនេះ ខ្ញុំសូមសម្ដែងនូវការដឹងគុណដ៏ជ្រាលជ្រៅ ជូនចំពោះឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលតែងតែផ្ដល់ឱវាទដឹកនាំដល់គណៈកម្មាធិ-

ការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងនាមជាសសរស្ដម្ភមួយនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ខ្ញុំសូមសម្ដែងមូលវិចារដ៏ថ្លៃវិសេសជូនដល់សម្ដេច ឯកឧត្ដម លោកជំទាវ ជារដ្ឋមន្ត្រី និងប្រធានស្ថាប័ន ដែលតែងតែដឹកនាំ និងគាំទ្រដល់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង-ស្ថាប័ន ព្រមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលបាននិងកំពុងចូលរួមចំណែកអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយស្មារតី និងសតិសម្បជញ្ញៈ នៃភាពជាម្ចាស់ ការទទួលខុសត្រូវខ្ពស់ និងភាពជាអ្នកដឹកនាំគម្រូលើការងារកែទម្រង់ រហូតសម្រេចបានសមិទ្ធផលដ៏វិសេសនាពេលនេះ។

ជាចុងក្រោយ ខ្ញុំសូមសម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលតែងតែគាំទ្រ ទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស តាមរយៈកិច្ចសហការ និងកិច្ចសម្របសម្រួលជាប្រចាំជាមួយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៕■

ថ្ងៃ សុក្រ ០៥កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

ចាប់តាំងពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានកំណត់ជាអាទិភាពគន្លឹះក្នុងគោលដៅផ្លាស់ប្តូរប្រព័ន្ធថវិកាឱ្យស្របតាមស្តង់ដារអន្តរជាតិ ទៅតាមយុទ្ធសាស្ត្រជាដំណាក់កាល។ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ. គ. ហ.) ដែលជាសេនាធិការរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានសម្របសម្រួលការរៀបចំ និងតាមដានការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង- ស្ថាប័ន។

លើសពីនេះ អ. គ. ហ. ក៏បានដាក់ចេញនូវយុទ្ធសាស្ត្រក្នុងការលើកកម្ពស់ និងជំរុញការចូលរួមពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ រួមមានជាអាទិ៍ សិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ចូលរួមជាមួយស្ថាប័នពាក់ព័ន្ធ,ការផ្សព្វផ្សាយតាមសារព័ត៌មាន, បណ្តាញទំនាក់ទំនងសង្គម, គេហទំព័រ និងការរៀបចំឯកសារសម្រាប់ចែកជូនសាធារណៈ ជាដើម។ ទន្ទឹមនេះ ការរៀបចំព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ជាឧបករណ៍មួយសំខាន់ផងដែរក្នុងការចែករំលែកនូវព័ត៌មាន និងចំណេះដឹងពាក់ព័ន្ធនានាសម្រាប់ជាប្រយោជន៍ជូនមន្ត្រីរាជការ សិស្ស- និស្សិត សម្រាប់សិក្សាឈ្វេងយល់បន្ថែមផងដែរ។ ជាក់ស្តែងរហូតមកដល់បច្ចុប្បន្ន អ. គ. ហ. បានរៀបចំ និងបោះផ្សាយព្រឹត្តិបត្រចំនួន ៣ លេខរួចមកហើយ។ សម្រាប់លេខ ៤ នេះ អ. គ. ហ. បានរៀបចំកែសម្រួលនូវរចនាសម្ព័ន្ធនៃការរៀបចំក្នុងក្របខណ្ឌនៃនវានុវត្តន៍ និងរក្សានូវគុណតម្លៃនៃព័ត៌មាន និងចំណេះដឹងដែលបានរៀបចំសម្រាប់ផ្សព្វផ្សាយ។

ជាការពិតណាស់ ឆន្ទៈ និងការចូលរួមប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ពីគ្រប់តួអង្គពាក់ព័ន្ធ បានចូលរួមចំណែកជាគុណតម្លៃយ៉ាងសំខាន់សម្រាប់កិច្ចការនានាក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងស្មារតីនេះ អ. គ. ហ បានខិតខំប្រមូលផ្តុំ និងចងក្រងនូវឯកសារ, អនុសាសន៍របស់ថ្នាក់ដឹកនាំ, បទពិសោធន៍ និងគំនិតថ្មីៗ ជាច្រើនពាក់ព័ន្ធនឹងការងារកែទម្រង់ហើយបានរំលេចចេញតាមរយៈព្រឹត្តបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅចែករំលែក បង្កើនការគាំទ្រ និងការចូលរួម ក៏ដូចជាបញ្ញាបពុទ្ធិ និងលើកកម្ពស់ការយល់ដឹងអំពីសារៈប្រយោជន៍នៃការងារកែទម្រង់។

អ. គ. ហ ជឿជាក់ថាព្រឹត្តបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ នឹងក្លាយទៅជាឧបករណ៍ជំនួយស្មារតី និងតម្លៃបន្ថែមជូនមន្ត្រីរាជការជាពិសេសសាធារណជន។ លើសពីនេះ អ. គ. ហ ក៏សូមចូលរួមវាយតម្លៃខ្ពស់ជូនចំពោះគ្រប់តួអង្គពាក់ព័ន្ធដែលតែងតែចូលរួម និងគាំទ្រការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមរូបភាពផ្សេងៗ ដែលនេះគឺជាឧត្តមវិភាគទានសម្រាប់ប្រជាជាតិខ្មែរ៕■

ថ្ងៃ ច័ន្ទ ០១កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព. ស. ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៧

**អគ្គលេខាធិការ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ**

**ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**



**រស់ សីលវ៉ា**

# មាតិកា

## ព្រឹត្តិការណ៍


១ សិក្ខាសាលាអន្តរជាតិ ស្តីពី “មេរៀន និងបទពិសោធន៍ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ÷ អភិក្រមសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយចីរភាពនៅកម្ពុជា”

៧ ការចុះផ្សព្វផ្សាយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដល់មន្ត្រីរាជការថ្នាក់ក្រោមជាតិ

៩ កម្មវិធីសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលស្តីពី “ក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ”


## អត្ថបទ


ឥទ្ធិពលនៃកម្មវិធីកែទម្រង់ក្នុងប្រព័ន្ធថវិកាសាធារណៈ ១៣

ការស្ទង់មតិ និងសន្ទស្សន៍ថវិកាបើកឆ្នាំ២០១៧ ១៥

គណនេយ្យភាពវិស័យសាធារណៈ ÷ បទពិសោធន៍នៃចក្រភពអង់គ្លេស ២០

ប្រព័ន្ធថវិកាប្រទេសម៉ាឡេស៊ី ២៣

# ទស្សនៈ និងមតិ


**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ២៥

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២៥

ឯកឧត្តម **George Edgar** ឯកអគ្គរដ្ឋទូត និងជាប្រធានសភាសហភាពអ៊ឺរ៉ុបនៅកម្ពុជា ២៦

លោកស្រី **Leah April** មន្ត្រីឯកទេសជាន់ខ្ពស់វិស័យសាធារណៈជំនាញសកលផ្នែកអភិបាលកិច្ចធនាគារពិភពលោក ២៦


តើអ្វីជា
PEFA?




# ផ្នែកទី ១ ÷ ព្រឹត្តិការណ៍



# សិក្ខាសាលាអន្តរជាតិស្តីពី "មេរៀន និងបទពិសោធន៍ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ÷ អភិក្រមសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយចីរភាពនៅកម្ពុជា"

នេះគឺជាលើកទី ២ ហើយ ដែលគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានរៀបចំសិក្ខាសាលាអន្តរជាតិក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សិក្ខាសាលានេះ រៀបចំ និងសម្របសម្រួលក្រោមកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារពិភពលោក និងត្រូវបានរៀបចំឡើងក្នុងគោលបំណងចែករំលែកនូវមេរៀន និងបទពិសោធន៍ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរវាងរាជ-



ជានិរន្តរភាពនៃការងារកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈ និងការងារកែទម្រង់ពាក់ព័ន្ធ។

សម្រាប់កម្ពុជា កម្មវិធីកែទម្រង់ការ-គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមអភិក្រមជាខឿន ត្រូវបានសម្រេចដោយជោគជ័យជាបន្តបន្ទាប់នូវជំហានទី១ និងទី២ ហើយបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ ក្នុងដំណាក់កាលទី៣នេះ ថវិកាកម្មវិធីគឺមានសារៈសំខាន់ក្នុងការប្រែក្លាយថវិកាទៅជាឧបករណ៍គោលនយោបាយយ៉ាងពិតប្រាកដក្នុងការបម្រើសេវាសាធារណៈជូនប្រជាពល-រដ្ឋ។ ជាលទ្ធផល ក្រសួង-ស្ថាប័នចំនួន ១០ បានអនុវត្តថវិកាកម្មវិធីពេញលេញត្រឹមឆ្នាំ២០១៥ និងឆ្នាំ២០១៦ ចំនួនសរុប ២៥, ឆ្នាំ២០១៧ ចំនួន ៣៦ និងឆ្នាំ២០១៨ គ្រប់ក្រសួងស្ថាប័ននឹងត្រូវអនុវត្តថវិកាកម្មវិធីពេញលេញតែម្តង។ ដោយឡែកសម្រាប់ការប្រើប្រាស់អភិក្រមបែបដកពិសោធន៍សម្រាប់អនុវត្តកំណែទម្រង់វិស័យសាធារណៈនៅអាស៊ី ជួបប្រទះនូវបញ្ហាប្រឈមគន្លឹះៗមួយចំនួន។ ដូចនេះ ដៃគូអភិវឌ្ឍន៍ និងរដ្ឋាភិបាលនានាបានបង្កើតនូវអភិក្រមដើម្បីគ្រប់គ្រងកិច្ចការបច្ចេកទេស ប្រព័ន្ធគាំទ្រ និងក្របខណ្ឌថ្មីសម្រាប់ដោះស្រាយបញ្ហាដ៏ស្មុគស្មាញដោយបន្សុំនូវឧត្តមានុវត្តន៍អន្តរជាតិ (Best Practice) និងដំណោះស្រាយសមស្របបំផុត(Best Fit)។ ជាក់ស្តែង ជំនាញការអន្តរជាតិបានចែករំលែកនូវការអនុវត្តតាមអភិក្រមសមស្របបំផុត (Best Fit) របស់ប្រទេសមួយចំនួនក្នុងតំបន់រួមមាន÷

*ភាពជាអ្នកដឹកនាំថ្នាក់កំពូល និងការប្តេជ្ញាខ្ពស់ ព្រមទាំងកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធគឺជាកត្តា-លីករជំរុញភាពជោគជ័យ នៃការងារកែទម្រង់ ជាពិសេសការកសាងសមត្ថភាពធនធានមនុស្ស បូករួមទាំងសមត្ថភាពវិភាគផងដែរ។*

- ប្រទេសឥណ្ឌូនេស៊ី ÷ គ្រប់ក្រសួង-ស្ថាប័នជំនាញទាំង ៨២ បាននិងកំពុងអនុវត្តនូវកំណែទម្រង់មុខងារសាធារ-ណៈដែលមានលក្ខណៈជាប្រព័ន្ធចាប់

រដ្ឋាភិបាលកម្ពុជា និងប្រទេសដទៃតាមរយៈវាគ្មិនកម្ពុជា និងជំនាញការអន្តរជាតិជាអភិ-ក្រមដកពិសោធន៍លើការអនុវត្តការងារកែទម្រង់ ព្រមទាំងជាកាលានុវត្តភាពថ្មីមួយទៀតសម្រាប់បញ្ជ្រាបការយល់ដឹងបង្កើនការចូលរួម និងជំរុញការផ្តល់នូវធាតុចូលដែលជាគុណតម្លៃបន្ថែមសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការលើការជំរុញប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏ដូចជាកិច្ចបង្កើនសហប្រតិបត្តិការក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍នានាក្នុងគោលដៅ






តាំងពីឆ្នាំ ២០១៥ មកម្លេះ។ រដ្ឋាភិបាលបានបើកចំហការជ្រើសរើសមន្ត្រីឱ្យចូលបម្រើការងារសម្រាប់មុខតំណែងស្ថូលឬយុទ្ធសាស្ត្រក្នុងមុខងារសាធារណៈ ដោយផ្តោតលើមុខតំណែងសំខាន់ៗមួយចំនួនដូចជាអគ្គនាយក រដ្ឋមន្ត្រីស្តីទី និងនាយកប្រតិបត្តិ/អគ្គលេខាធិការនៅតាមក្រសួង និងស្ថាប័នជំនាញ។ ប្រទេសឥណ្ឌូនេស៊ី បានប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងលើហិរញ្ញវត្ថុសាធារណៈ (FMIS) ឬប្រព័ន្ធថវិកា និងរតនាគាររដ្ឋ(SPAN) ដែលបានប្រកាសដាក់ឱ្យអនុវត្តនៅក្នុងខែមេសា ឆ្នាំ២០១៥ ដោយប្រធានាធិបតី លោកJoko Widodo។ SPAN គឺជាសមាសភាគដ៏សំខាន់នៃគម្រោងរដ្ឋបាលចំណូល និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល (Government Financial Management and Revenue Administration Project) ដែលគម្រោងនេះត្រូវបានគាំទ្រផ្នែកហិរញ្ញវត្ថុដោយធនាគារពិភពលោកចាប់តាំងពីឆ្នាំ២០០៤។

▶ ប្រទេសម៉ាឡេស៊ី ÷ កម្មវិធីការផ្លាស់ប្តូររបស់រាជរដ្ឋាភិបាល (Government Transformation Program) ត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ ២០១០ ដើម្បីលើកកម្ពស់ប្រព័ន្ធឆ្ពោះទៅរកសមិទ្ធកម្ម គណនេយ្យភាព និងឆ្លើយតបទៅនឹងតម្រូវការនៃរាជរដ្ឋាភិបាល។ ដោយឡែក ក្របខណ្ឌផ្លាស់ប្តូរសេវាសាធារណៈ (Public Service Transformation Framework) ត្រូវបានប្រកាសដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០១៣ ដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធធនធានមនុស្សដើម្បីឆ្លើយតបនឹងរបៀវារៈនៃកម្មវិធីផ្លាស់ប្តូរជាតិ(National Transformation Agenda) ក្នុងគោលដៅធានាការប្រកួតប្រជែងជាសកល និងសម្រេចបាននូវទស្សនៈវិស័យឆ្នាំ ២០២០។ ជាឧត្តមានុវត្តន៍ ម៉ាឡេស៊ីបានប្រើប្រាស់អភិក្រមពីលើចុះក្រោម និងពីក្រោមឡើងលើក្នុងការដោះស្រាយបញ្ហាប្រឈមដោយផ្អែកលើគំនិតបែបនវានុវត្តន៍។ លើសពីនេះ ភាពជាអ្នកដឹកនាំថ្នាក់កំពូល និងការប្តេជ្ញាខ្ពស់ ព្រមទាំងកិច្ចសហការរវាងក្រសួងស្ថាប័នពាក់ព័ន្ធគឺជាកត្តាលីករជំរុញភាពជោគជ័យនៃការងារកែទម្រង់ ជាពិសេសការកសាងសមត្ថភាពធនធានមនុស្ស ប្ញករួមទាំងសមត្ថភាពវិភាគផងដែរ។

*សម្រាប់កម្ពុជាកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមអភិក្រមជាខឿនត្រូវបានសម្រេចដោយជោគជ័យជាបន្តបន្ទាប់នូវជំហានទី១ និងទី២ ហើយបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលទី ៣ គឺ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"*

▶ ប្រទេសថៃ ÷ ធនាគារពិភពលោកបានផ្តល់ហិរញ្ញប្បទានដល់ប្រទេសថៃក្នុងឆ្នាំ ១៩៩៩ តាមរយៈកម្ចីកំណែទម្រង់វិស័យ






សាធារណៈ (Public Sector Reform Loan) និងកម្ចីហិរញ្ញប្បទានគ្រប់គ្រងសេដ្ឋកិច្ច (Economic Management Assistant Loan) បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុអាស៊ានបានវាយប្រហារទៅលើប្រទេសខ្លួនកាលពីឆ្នាំ ១៩៩៧។ ថៃបានចាប់យកការរៀបចំថវិកាផ្អែកលើសមិទ្ធកម្មយុទ្ធសាស្ត្រ (Strategic Performance Base Budgeting) ដែលក្របខណ្ឌនេះត្រូវបានរៀបចំដោយផ្អែកលើឧត្តមានុវត្តន៍របស់ប្រទេសណូវ៉ែលហ្សឺឡង់ ហូឡង់ ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងអូស្ត្រាលី។ ជាឧត្តមានុវត្តន៍ ថៃបានជំនះនូវបញ្ហាប្រឈមដោយប្រើប្រាស់អភិក្រមសាកល្បង (Pilot Approach) ក្នុងការធ្វើតេស្ត 7 Hurdle Approach រួមមាន ÷ ការរៀបចំផែនការថវិកា (budget planning), ការធ្វើតម្រូវការចំណាយតាមធាតុចេញ (output costing), ការគ្រប់គ្រងលទ្ធកម្ម (procurement management), ការគ្រប់គ្រងថវិកា និងមូលនិធិ (budget and funds control), ការរៀបចំរបាយការណ៍សមិទ្ធកម្មនិងហិរញ្ញវត្ថុ (financial and performance reporting), ការគ្រប់គ្រងទ្រព្យសកម្ម (asset management), និងសវនកម្មផ្ទៃក្នុង (internal audit), និងតាមរយៈការរៀបចំថវិកាផ្អែកលើសមិទ្ធកម្ម (Performance Base Budgeting) និងការចុះហត្ថលេខាលើអនុសារណៈយោគយល់ដើម្បីបង្ហាញពីប្រតិជ្ញា និងការរៀបចំសិក្ខាសាលាដើម្បីពង្រឹងសមត្ថភាព ដោយគួបផ្សំនឹងកត្តាមួយចំនួនទៀតមានជាអាទិ៍÷ ការយល់ដឹង និងការប្ដេជ្ញាផ្នែកនយោបាយ ការត្រៀមលក្ខណៈសម្រាប់ការអនុវត្ត និងអំណាចនៃការផ្ដោត (Power of Focus)។

▶ វៀតណាម ÷ វៀតណាមបានបង្កើតច្បាប់ថវិការដ្ឋ (State Budget Law) ឆ្នាំ ១៩៩៦ ដែលផ្ដោតទៅលើប្រតិទិនដំណើរការ និងគោលការណ៍ថវិកាប្រចាំឆ្នាំ។ នៅឆ្នាំ២០០២ វៀតណាមបានធ្វើវិសោធនកម្មច្បាប់ថវិការដ្ឋដែលផ្ដោតលើវិមជ្ឈការថវិកាទៅថ្នាក់ខេត្ត និងនៅក្នុងឆ្នាំ២០១៣ បានចាប់ផ្ដើមបង្កើតប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងលើថវិកា និងគណនេយ្យរតនាគារ (Treasury Accounting and Budgeting Management Information System) (TABMIS)។ រហូតមកដល់ឆ្នាំ២០១៥ ច្បាប់ថវិការដ្ឋត្រូវបានធ្វើវិសោធនកម្មជាលើកទី ២ ដែលផ្ដោតការយកចិត្តទុកដាក់លើតម្លាភាពថវិកា និងក្របខណ្ឌថវិការយៈពេលមធ្យម។ ជាឧត្តមានុវត្តន៍ វៀតណាមបានជំនះរាល់បញ្ហាប្រឈមមានជាអាទិ៍ ÷ ភាពរឹងរុសក្នុងការទទួល



យកនូវប្រព័ន្ធថ្មី និងបញ្ហាសមត្ថភាព ដោយការប្ដេជ្ញាពីថ្នាក់ដឹកនាំកំពូលក្នុងការដាក់ចេញនូវបទបញ្ញត្តិចាំបាច់សម្រាប់ប្រតិបត្តិការប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងលើថវិកា និងគណនេយ្យរតនាគារ និងរៀបចំនូវវគ្គបណ្ដុះបណ្ដាលសម្រាប់មន្ត្រីក្នុងការិយាល័យរតនាគារទាំង ៧០០។

យ៉ាងណាមិញ សម្រាប់ប្រទេស ៣ ទៀតបានចែករំលែកនូវបទពិសោធន៍ក្នុងការអនុវត្តកម្មវិធីកែទម្រង់ផងដែរ រួមមាន ៖ ប្រទេសឡាវ បានសម្រេចនូវសមិទ្ធផលក្នុងការកែទម្រង់រតនាគារ ជំនាន់ទី ១ និងស្ថិតក្នុងកំណែទម្រង់ជំនាន់ទី ២ ដោយផ្ដោតសំខាន់លើការផ្ទេរចំណេះដឹង និងការកសាងសមត្ថភាពដើម្បីនិរន្តរភាពនៃការកែទម្រង់ ព្រមទាំងរៀបចំ និងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ហិរញ្ញវត្ថុសាធារណៈ ២០២៥ (Public Finance Development Strategy 2025) ដែលជាឯកសារយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយសម្រាប់បន្តការកែទម្រង់។ ស្រដៀងគ្នាផងដែរ



ប្រទេសប៉ាពួញូហ្គីណេ បានធ្វើកំណែទម្រង់ការរៀបចំហិរញ្ញវត្ថុអន្តររដ្ឋាភិបាល (Intergovernmental Finance Arrangements) រយៈពេល ៧ ឆ្នាំ (២០០៣-២០១០) គឺផ្តោតការយកចិត្តទុកដាក់លើថ្នាក់ខេត្ត។ ដោយឡែកសម្រាប់ប្រទេសមីយ៉ាន់ម៉ា ក៏កំពុងស្ថិតក្នុងដំណាក់កាលនៃការចាប់ផ្តើមនូវកម្មវិធីកែទម្រង់ជាបន្តបន្ទាប់។



ជារួម ការងារកែទម្រង់គឺជាការសម្រេចយកនូវភាពឈើចាប់ដ៏ធំធេងជាមួយនឹងរបត់នៃការអនុវត្តតាមបែបផែនដែលពុំមានប្រសិទ្ធភាព ឱ្យទៅជាការអនុវត្តកិច្ចការក្នុងវិស័យសាធារណៈប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព ដើម្បីឧត្តមយោជន៍ជាតិដែលត្រូវបានយកចិត្តទុកដាក់ខ្ពស់៕



# ការផ្សព្វផ្សាយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដល់មន្ត្រីរាជការថ្នាក់ក្រោមជាតិ




កាលពីឆ្នាំ២០១៦ កន្លងទៅ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានផ្សព្វផ្សាយកម្មវិធីកែទម្រង់ជូនដល់មន្ត្រីរាជការតាមក្រសួងស្ថាប័ន។ ដោយឡែកសម្រាប់ឆ្នាំ ២០១៧ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងត្រូវបានពង្រីកការផ្សព្វផ្សាយជូនដល់មន្ត្រីរាជការថ្នាក់មូលដ្ឋានតាមរាជធានីខេត្តទាំង២៥។

ជាក់ស្តែង ក្នុងកំឡុងខែឧសភា និងកក្កដា ឆ្នាំ២០១៧ កន្លងទៅនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) សហការជាមួយរដ្ឋបាលរាជធានី-ខេត្ត រៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅសាលារដ្ឋបាលរាជធានី-ខេត្ត រួមមាន (១) រាជធានីភ្នំពេញ, (២) ខេត្តកំពង់ឆ្នាំង, (៣) ខេត្តកំពង់ស្ពឺ, (៤) ខេត្តកណ្តាល និង (៥) ខេត្តតាកែវ។ កម្មវិធីផ្សព្វផ្សាយតាមបណ្តារាជធានី-ខេត្ត មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ជាតំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមមាន ឯកឧត្តម **ឆាន់ ទឡ្ហៈ** ទទួលបន្ទុកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីភ្នំពេញ, ឯកឧត្តម **រស់ សីលវ៉ា** ទទួលបន្ទុកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំង, លោកជំទាវ **កែវ ចរិយា** ទទួលបន្ទុកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកណ្តាល និង ឯកឧត្តម **អៀង ស៊ុនលី** ទទួលបន្ទុកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តតាកែវ។ រីឯថ្នាក់ដឹកនាំតាមបណ្តារដ្ឋបាលរាជធានី-ខេត្ត ចូលរួមជាអធិបតីភាព រួមមាន លោក **មាន ចាន់យ៉ាដា** អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ, លោក **ហេង ពិទូ** អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង,






លោក **ចាន់ តារា** អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ស្ពឺ, លោក **នួន ម៉េងចំនួនដារា** ភិបាលរងនៃគណៈអភិបាលខេត្តកណ្តាល និងលោក **យស់ ណាស៊ី** អភិបាលរងនៃគណៈអភិបាលខេត្តតាកែវ។ ទន្ទឹមនឹងនេះ តំណាងអគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានអញ្ជើញចូលរួមធ្វើបទអន្តរាគមន៍ និងឆ្លើយសំណួរដែលទាក់ទងនឹងបញ្ហាប្រឈមការអនុវត្តការងារប្រចាំថ្ងៃផង និងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ។ ការផ្សព្វផ្សាយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺមានគោលបំណងជំរុញ, បង្កើនការយល់ដឹង និងការចូលរួមការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងមន្ត្រីរាជការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ មូលហេតុចំបងដែលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវលើកយកមកផ្សព្វផ្សាយដល់មន្ត្រីរាជការថ្នាក់ក្រោមជាតិឱ្យបានទូលំទូលាយ គឺរដ្ឋបាលរាជធានី-ខេត្តនឹងចាប់ផ្តើមអនុវត្តថវិកាកម្មវិធីជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០១៧-២០២០។ នៅក្នុងឆ្នាំ២០១៧ មានរដ្ឋបាលខេត្តចំនួន ០៦ ត្រូវបានជ្រើសរើស និងដាក់ឱ្យអនុវត្តថវិកាកម្មវិធី ដោយក្នុងនោះរួមមាន ខេត្តកំពង់ស្ពឺ ខេត្តកែប, ខេត្តកោះកុង, ខេត្តប៉ៃលិន, ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។ ការដាក់ឱ្យអនុវត្តថវិកាកម្មវិធីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺស្របតាមទិសដៅ "ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៣-២០២០" ក្នុងគោលដៅបោះជំហានឆ្ពោះទៅកាន់ការកែប្រែប្រព័ន្ធថវិកាទាំងស្រុងពី "ប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមជ្ឈការ" ទៅជា "ប្រព័ន្ធថវិកាផ្តោតលើលទ្ធផលឬធាតុចេញ និងវិមជ្ឈការ"។ ឆ្លងតាមការរៀបចំការចុះផ្សព្វផ្សាយកម្មវិធីកែទម្រង់នេះ រដ្ឋបាលរាជធានីខេត្តទាំង ០៥ បានកោតសរសើរ និងថ្លែងអំណរគុណចំពោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានចុះផ្សព្វផ្សាយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ និងជួយដោះស្រាយបញ្ហាប្រឈមនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។



*ការផ្សព្វផ្សាយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺមានគោលបំណងជំរុញ បង្កើនការយល់ដឹង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមន្ត្រីរាជការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ*

ជារួម មន្ត្រីរាជការថ្នាក់ក្រោមជាតិប្រមាណជា ១០០០ នាក់ បានយល់ដឹង និងទទួលស្គាល់នូវវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគាំទ្រការងារកែទម្រង់ដែលរាជរដ្ឋាភិបាលបានចាត់ទុកថាជាការងារអាទិភាពដែលបម្រើឱ្យគោលនយោបាយរបស់រាជរដ្ឋាភិបាល។ អ.គ.ហ. នឹងធ្វើការផ្សព្វផ្សាយនៅតាមខេត្តផ្សេងៗទៀតជាបន្តបន្ទាប់៕

# កម្មវិធីសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ស្តីពី "ក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ"

នៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៧ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) សហការជាមួយលេខាធិការដ្ឋានគណនេយ្យភាពហិរញ្ញវត្ថុ និងចំណាយសាធារណៈ បានរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលស្តីពី "ក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ"។

សិក្ខាសាលានេះ ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃអ.គ.ហ. និងជាតំណាងឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃ អ.គ.ហ.។ ការរៀបចំសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលស្តីពីក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ ត្រូវបានរៀបចំជាលើកទី១ នៅក្នុងប្រទេសកម្ពុជាដែលមានគោលបំណងបញ្ជ្រាបការយល់ដឹងអំពីក្របខណ្ឌសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមស្តង់ដារអន្តរជាតិ និងពង្រឹងសមត្ថភាពមន្ត្រីរាជការលើការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** បានគូសបញ្ជាក់ថា ក្របខណ្ឌ PEFA គឺជាឧបករណ៍វាស់ស្ទង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល ដែលចង្អុលបង្ហាញប្រាប់អំពីចំណុចខ្លាំង និងចំណុចខ្សោយនៃប្រព័ន្ធថវិកា និងវដ្តថវិកាទាំងមូល ចាប់តាំងពីការរៀបចំថវិកា, ការអនុវត្តថវិកា និងការត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តថវិកា។

លទ្ធផលនៃការវាយតម្លៃតាមក្របខណ្ឌ PEFA គឺជាធាតុចូលដ៏សំខាន់សម្រាប់ការរៀបចំផែនការសកម្មភាព និងការកំណត់អាទិភាវូបនីយកម្មកែទម្រង់ជាជំហានៗឱ្យបានត្រឹមត្រូវ និងប្រាកដនិយមផ្សារភ្ជាប់នឹងស្ថានការណ៍ជាក់ស្តែង។

មិនតែប៉ុណ្ណោះ ការវាយតម្លៃតាមក្របខណ្ឌ PEFA អនុញ្ញាតឱ្យយើងអាចប្រៀបធៀប





ប្រព័ន្ធគ្រប់គ្រងថវិការបស់កម្ពុជាយើងទៅនឹងប្រព័ន្ធគ្រប់គ្រងថវិកានៃបណ្ដាប្រទេសផ្សេងទៀតនៅលើមូលដ្ឋានគ្រឹះ ៣ យ៉ាង គឺ ÷ បូរណភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាពនៃការវិភាជថវិកា និងស័ក្តិសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ។ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានរៀបចំរបាយការណ៍វាយតម្លៃ PEFA លើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាចំនួន ២ ដង រួចមកហើយ គឺរបាយការណ៍ PEFA លើកទី១ ដែលត្រូវបានរៀបចំ និងផ្សព្វផ្សាយក្នុងឆ្នាំ ២០១០ សម្រាប់ការវាយតម្លៃការអនុវត្តក្នុងឆ្នាំ ២០០៦, ២០០៧ និងឆ្នាំ២០០៨ រីឯរបាយការណ៍ PEFA លើកទី២ ត្រូវបានរៀបចំរួចរាល់ និងផ្សព្វផ្សាយនៅក្នុងឆ្នាំ២០១៥ សម្រាប់ការវាយតម្លៃការអនុវត្តចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៤។ នៅលើកទី១ ឆ្នាំ២០១០ ការវាយតម្លៃត្រូវបានរៀបចំដោយក្រុមទីប្រឹក្សាអន្តរជាតិ រីឯក្រសួង-ស្ថាប័នកម្ពុជា គឺជាអ្នកចូលរួម, ចំណែកឯការវាយតម្លៃលើកទី២ នៅឆ្នាំ២០១៥ គឺដឹកនាំអនុវត្តផ្ទាល់ដោយ អ.គ.ហ. និងមានការរួមចំណែកវាយតម្លៃទាំងអស់គ្នាពីគ្រប់អង្គភាព និងក្រសួង-ស្ថាប័នកម្ពុជា រីឯទីប្រឹក្សាអន្តរជាតិជាអ្នកចូលរួមក្នុងការពិនិត្យគុណភាពនៃរបាយការណ៍ធៀបទៅនឹងស្តង់ដារអន្តរជាតិវិញម្តង។



លោក **យ៉េត វីណៃល** អគ្គលេខាធិការរងនៃ អ.គ.ហ. បានលើកឡើងថា ការប្រើប្រាស់ឧបករណ៍ PEFA គឺដើម្បីវាស់វែងអំពីសុខភាពប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ តាមរយៈលទ្ធផលវាយតម្លៃ PEFA គឺមិនត្រឹមតែជាធាតុចូលសម្រាប់រៀបចំក្របខណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី២ និងដំណាក់កាលទី៣ ប៉ុណ្ណោះទេ តែថែមទាំងបង្កើនសមត្ថភាពមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផងដែរលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

លោក Lewis Hawke ប្រធានលេខាធិការដ្ឋាន PEFA បានជម្រាបអង្គសិក្ខាសាលាថា ការប្រើប្រាស់ក្របខណ្ឌ PEFA ជាឧបករណ៍សម្រាប់ការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបានផ្តល់អត្ថប្រយោជន៍ចំនួន ០៤ រួមមាន÷




វាស់វែងវឌ្ឍនភាពប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ពង្រឹងចលនការនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ និងការទទួលស្គាល់ជាអន្តរជាតិ។

ក្របខណ្ឌ PEFA ឆ្នាំ២០១៦ ត្រូវបានបែងចែកជាលទ្ធផលចុងក្រោយចំនួន ០៣, សសរស្ដម្ភចំនួន០៧, សូចនាករសមិទ្ធកម្មចំនួន ០៧ និងសមាសធាតុចំនួន ៩៤។ លោក Lewis Hawke បានបន្ថែមថា ភាពខុសប្លែកគ្នារវាងក្របខណ្ឌ PEFA ឆ្នាំ២០១១ និងក្រខណ្ឌ PEFA ឆ្នាំ២០១៦ មានចំណុចមួយចំនួនដោយក្របខណ្ឌឆ្នាំ ២០១៦ បានបន្ថែមនូវការគ្រប់គ្រងទ្រព្យសកម្ម, យុទ្ធសាស្ត្រក្របខណ្ឌចំណូលចំណាយ, ក្របខណ្ឌវិនិយោគសាធារណៈ និងលុបមួយផ្នែកស្ដីពីជំនួយរបស់ដៃគូអភិវឌ្ឍន៍។ តាមរយៈការបណ្ដុះបណ្ដាល ដោយធ្វើលំហាត់អនុវត្តពិន្ទុដែលទទួលបានសម្រាប់ក្រសួង-ស្ថាប័ន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមធ្យមប្រមាណ ៦៤% នៃ ១០០%។ លទ្ធផលនេះ បង្ហាញថា កម្រិតយល់ដឹងរបស់មន្ត្រីរាជការមានការកើនឡើង បើប្រៀបធៀបការស្ទង់មតិលើកដំបូង ដែលស្ទើរតែ ១០០% មិនធ្លាប់ដឹងលឺអំពីក្របខណ្ឌ PEFA ពីមុនមក។

*ក្របខណ្ឌ PEFA ឆ្នាំ ២០១៦ ត្រូវបានបែងចែកជាលទ្ធផលចុងក្រោយចំនួន ០៣, សសរស្ដម្ភចំនួន០៧, សូចនាករសមិទ្ធកម្មចំនួន ០៧ និងសមាសធាតុចំនួន ៩៤។*

ជារួម មន្ត្រីរាជការគ្រប់ក្រសួង-ស្ថាប័នបានទទួលចំណេះដឹងសំខាន់ៗ ដូចខាងក្រោម÷

- យល់ដឹងអំពីទស្សនាទាន និង



សារៈសំខាន់នៃការប្រើប្រាស់ក្របខណ្ឌ PEFA ក្នុងការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងមានលទ្ធភាពក្នុងការបកស្រាយរបាយការណ៍ចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុឆ្នាំ២០១៥។




- យល់ដឹងអំពីភាពខុសប្លែកគ្នារវាងក្របខណ្ឌ PEFA ឆ្នាំ២០១១ និងក្របខណ្ឌ PEFA ឆ្នាំ២០១៦។
- មានលទ្ធភាពកំណត់ភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងអាចរៀបចំផែនការសកម្មភាពដើម្បីដោះស្រាយនូវចំណុចខ្សោយនៃប្រព័ន្ធ ជាពិសេសការយកលទ្ធផលពីការវាយតម្លៃ PEFA ឆ្នាំ២០១៥ ទៅប្រើប្រាស់ជាធាតុចូលសម្រាប់ CAP3។
- ដំណើរការ, វិធីសាស្ត្រវាយតម្លៃ និងទម្រង់របាយការណ៍ PEFA ទាំងក្របខណ្ឌ PEFA ឆ្នាំ២០១១ និងក្របខណ្ឌ PEFA ឆ្នាំ២០១៦។■




តើអ្វីជា
PEFA?




# ផ្នែកទី ២ ÷ អត្ថបទ

# ឥទ្ធិពលនៃកម្មវិធីកែទម្រង់ក្នុងប្រព័ន្ធ ថវិកាសាធារណៈ

ជាការពិត លទ្ធផលដែលទទួលបានជាវិជ្ជមាន គឺជាសមិទ្ធផលដែលផុសចេញពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈ ៤ ដំណាក់កាលដែលរាជរដ្ឋាភិបាលបានគិតគូរ និងដាក់ចេញចាប់តាំងពីឆ្នាំ២០០៤ ក្នុងគោលដៅនៃការផ្លាស់ប្តូរប្រព័ន្ធថវិកាជាតិស្របតាមស្តង់ដារអន្តរជាតិ។

ជាក់ស្តែង តាមរយៈការផ្លាស់ប្តូរនេះ ភាពជឿទុកចិត្តនៃថវិកានៃដំណាក់កាលទី ១ បានផ្តល់លទ្ធភាពឱ្យលំហូរនៃចំណូលកាន់តែរលូន អនុញ្ញាតឱ្យការវិភាជថវិកាចំគោលដៅ និងកាន់តែមានប្រសិទ្ធភាពជាងមុន ជាពិសេសបានប្រែក្លាយពីស្ថានភាពនៃ"កង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ" មកជាប្រទេសដែលមាន"អតិរេកសាច់ប្រាក់"។

*ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាមានចំណុចខ្លាំងលើការអនុវត្តថវិកាទាំងចំណូលនិងចំណាយ តម្លាភាពនៃទំនាក់ទំនងថវិកាអន្តររដ្ឋបាល ព្រមទាំងភ្ជាប់ទៅនឹងគោលបំណងគោលនយោបាយ និងគោលដៅរបស់រាជរដ្ឋាភិបាល*

ដោយឡែក សម្រាប់នីតិកាលទី៥នេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានបញ្ចប់ដោយជោគជ័យនូវដំណាក់កាលទី ២ គឺ "គណនេយ្យភាពហិរញ្ញវត្ថុ" ដែលផ្តោតលើការពង្រឹងប្រសិទ្ធភាព និងគណនេយ្យភាពហិរញ្ញវត្ថុដែលប្រែក្លាយពីភាពមិនច្បាស់-លាស់នៃប្រព័ន្ធកត់ត្រា និងរបាយការណ៍ឱ្យទៅជាប្រព័ន្ធទំនើបមួយដែលមានលក្ខណៈសុក្រឹតភាព ភាពទាន់ពេល និងការធ្វើមូលវិចារចំណូល និងចំណាយបានកាន់តែប្រសើរឡើង ក្នុងនោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារ-ណៈតាមបែបប្រព័ន្ធព័ត៌មានវិទ្យា (FMIS) ជាមួយនឹងការដាក់ឱ្យប្រើប្រាស់នៅពេលថ្មីៗនេះនូវចំណាត់ថ្នាក់ថវិកាទាំង៧ សម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធ។ បច្ចុប្បន្នកម្ពុជាកំពុងអនុវត្តនូវដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ផ្តោតជាសំខាន់លើការអនុវត្តថវិកាកម្មវិធីពេញលេញ និងការដាក់ឱ្យអនុវត្តអង្គភាពថវិកាដែលនៅឆ្នាំ២០១៨ នេះ គ្រប់ក្រសួង-ស្ថាប័នត្រូវអនុវត្ត ហើយក៏ជាដំណាក់កាលដ៏សំខាន់នឹងត្រូវបន្តអនុវត្តនៅក្នុងនីតិកាលថ្មីជាបន្តបន្ទាប់ទៀត។ ក្រៅពីនេះ រាជរដ្ឋាភិបាលបានកែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាបន្តបន្ទាប់តាមរយៈការរៀបចំនូវលិខិតបទដ្ឋានគតិ-យុត្តិដោយបានបញ្ចប់អនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌ សារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើ-ភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងបន្តបញ្ចប់ការ-រៀបចំនូវសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់-







គ្រងការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។

ជាងនេះទៅទៀត កម្ពុជាមានភាពជាម្ចាស់ក្នុងការរៀបចំវាយតម្លៃដោយខ្លួនឯងតាមក្របខ័ណ្ឌ PEFA ដើម្បីវាស់វែងអំពីសុខភាពប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ជាលទ្ធផល







ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាមានចំណុចខ្លាំងលើការអនុវត្តថវិកាទាំងចំណូលនិងចំណាយ តម្លាភាពនៃទំនាក់ទំនងថវិកាអន្តររដ្ឋបាល ព្រមទាំងការចូលរួមរបស់ក្រសួង- ស្ថាប័នក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលលទ្ធផលទាំងនេះបានជួយគាំទ្ររាជរដ្ឋាភិបាលក្នុងការពង្រឹងការអនុវត្តថវិកា និងការធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានហិរញ្ញវត្ថុសាធារណៈដែលផ្សារភ្ជាប់ទៅនឹងគោលបំណងគោលនយោបាយ និងគោលដៅរបស់រាជរដ្ឋាភិបាល។




ម៉្យាងវិញទៀត ស្ថាប័នអន្តរជាតិមួយចំនួនក៏បានវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា និងរំលេចតាមរយៈរបាយការណ៍ផ្សេងៗគ្នា ដែលក្នុងនោះលទ្ធផលវាយតម្លៃបានទទួលស្គាល់ថាកម្ពុជាសម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់លើការរៀបចំ និងដាក់ឱ្យអនុវត្តថវិកាកម្មវិធី និងការផ្ដួចផ្ដើម និងត្រៀមខ្លួនលើការរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា២០១៧-២០២៥ និងការរៀបចំប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈដែលត្រូវបានគិតគូរបញ្ចប់ការអនុវត្តក្នុងដំណាក់កាលទី៣ ព្រមទាំងកិច្ចសហការប្រកបដោយឆន្ទៈមោះមុតជាមួយនឹងកម្មវិធីកែទម្រង់ធំៗផ្សេងទៀត គឺកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិប-តេយ្យនៅថ្នាក់ក្រោមជាតិ៕■

# ការស្ទង់មតិ និងសន្ទស្សន៍ថវិកាបើកឆ្នាំ ២០១៧

ជាគោលការណ៍ “តម្លាភាពថវិកា” គឺជាការបើកចំហរចំពោះសាធារណជន អំពីប្រតិបត្តិការថវិកាទាំងក្នុងអតីតកាល, បច្ចុប្បន្នកាល និងអនាគតកាល ដែលឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋាភិបាល ក្នុងការកំណត់ពីគោលនយោបាយថវិកា និងលទ្ធផលដែលសម្រេចបាន។ ថែមលើនេះ ព័ត៌មានពាក់ព័ន្ធនឹងថវិកាពេញលេញត្រូវផ្សព្វផ្សាយឱ្យទាន់ពេលវេលា និងមានលក្ខណៈជាប្រព័ន្ធ។




តម្លាភាពថវិកា មានលក្ខណៈស្មុគស្មាញជាពិសេសនៅពេលដែលយើងកំណត់ថាតើអ្នកណាដែលនឹងប្រើប្រាស់ព័ត៌មានទាំងនោះ និងនៅក្នុងភាពលម្អិតកម្រិតណា? ការបើកចំហរព័ត៌មាន គឺគ្មានប្រយោជន៍ទេ ប្រសិនបើគ្មានប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃច្បាស់លាស់ពីប្រសិទ្ធភាពនៃការអនុវត្ត ជាទូទៅជាអ្វីត្រូវបានកសាងនៅក្នុងស្ថាប័ន ដែលទាមទារឱ្យមានជំនាញច្បាស់លាស់, ចំណេះដឹងខ្ពស់ និងភាពស្មោះត្រង់ក្នុងការបកស្រាយពន្យល់។ នៅក្នុងកម្រិតប្រទេស តម្លាភាពថវិកា គួរត្រូវបកស្រាយក្នុងលក្ខណៈប្រយ័ត្នប្រយែងបំផុត ពីព្រោះនិន្នាការពិភពលោកផ្តោតការយកចិត្តទុកដាក់លើជំហររួមនៃថវិកា មិនមែនជាចំណុចលម្អិតទាំងអស់ ដែលក្នុងករណីខ្លះអាចពាក់ព័ន្ធនឹងការសម្ងាត់របស់ជាតិ។ ប្រសិនបើតម្លាភាពថវិកាត្រូវបានប្រើប្រាស់ត្រឹមត្រូវ នឹងទទួលបានផលប្រយោជន៍ធំពីរយ៉ាង ÷

- ជាឧបករណ៍ដ៏មានតម្លៃចូលរួមចំណែកក្នុងការសម្រេចបានគោលបំណងនៃគោលនយោបាយសាធារណៈ មិនមែនមានន័យថាតម្លាភាពថវិកាអាចជួយឱ្យសម្រេចបាននោះទេ, និង

- ធានាបានប្រសិទ្ធភាព, គណនេយ្យភាព និងបញ្ចៀសនូវអំពើពុករលួយក្នុងការគ្រប់គ្រងថវិកា។ ឧទាហរណ៍ជាក់ស្តែង គឺអាចខ្ទីបំណុលក្នុងអត្រា

ការប្រាក់ទាប និងជាទូទៅមានឱនភាពថវិកា ព្រមទាំងបំណុលកម្រិតទាប។

អាស្រ័យហេតុនេះ ក្នុងការអនុវត្តជាក់ស្តែងពីតម្លាភាពថវិកា តែងជួបប្រទះនឹងបញ្ហាលំបាកធំពីរ÷

- ក្តីសង្ឃឹមខ្ពស់ពេក ឬតម្រូវការច្រើនពេក រួមទាំងទំហំរដ្ឋបាល, កម្រិតនៃឱនភាព និងបំណុល, គណនេយ្យភាព, ការឆ្លើយតបរបស់រដ្ឋាភិបាល និងការកាត់បន្ថយអំពើពុករលួយ ហេតុដូចនេះ ត្បិតមានអ្នកពាក់ព័ន្ធច្រើន ជាទូទៅធ្វើឱ្យការអនុវត្តខ្វះនូវភាពច្បាស់លាស់ដោយសារការដាក់បន្ទុកធ្ងន់ខ្លាំងពេកលើអ្នកបច្ចេកទេស និងត្រូវផ្តោតការយកចិត្តទុកដាក់លើដំណើរការជាជាងការដោះស្រាយបញ្ហា និងសំខាន់បំផុតមិនសម្រេចបានតាមគោលបំណងនៃគោលនយោបាយថវិកា និង
- បញ្ហាបច្ចេកទេស, វប្បធម៌ និងនយោបាយ ដែលជះឥទ្ធិពលដល់ទំនាក់ទំនងរវាងតម្លាភាព និងលក្ខណៈពិសេសផ្សេងៗនៃថវិកា ជាពិសេសគេមិនដឹងថាតើតម្លាភាពថវិកាអាចជួយដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ ដូចជាការពង្រឹងការប្រកួតប្រជែង ឬធម្មភាពនៃឱនភាពបានដែរឬអត់? ឧទាហរណ៍ បំណុលសហរដ្ឋអាមេរិក និងបំណុលសហភាពសូវៀតនៅកម្ពុជា, តើតម្លាភាពថវិកានឹងធ្វើឱ្យបំណុលទាំងអស់នោះទៅជាស្របច្បាប់? ឬអាចលុបចេញបានដែរឬទេ?

## ការស្ទង់មតិថវិកាបើក មានគោលបំណង ០៥ សំខាន់ៗ ដូចតទៅ÷

- បង្កើនការយល់ដឹងពីសារៈសំខាន់នៃតម្លាភាព, ការចូលរួម និងគណនេយ្យភាពក្នុងកិច្ចដំណើរការ និងតម្លៃព្រមទាំងអត្ថប្រយោជន៍
- បង្កើនការយល់ដឹងជាទូទៅពីការស្ទង់មតិថវិកាបើក, គោលបំណង, ការគ្របដណ្តប់ និងវិធីសាស្ត្រ (ក្នុងលក្ខខណ្ឌដំណើរការ និងមាតិកា)
- ទទួលយកចំណេះដឹង និងឧបករណ៍ផ្តល់មតិយោបល់ពីបណ្តាប្រទេសនីមួយៗ
- បំពេញតារាងសំណួរពាក់ព័ន្ធការស្ទង់មតិថវិកាបើករបស់ប្រទេសនីមួយៗ សម្រាប់ផ្នែកត្រួតពិនិត្យឡើងវិញដោយរួមមានការប្តេជ្ញាខ្ពស់ក្នុងការផ្តល់មតិយោបល់ប្រកបដោយគុណភាព និងរួមចំណែកដល់សេចក្តីព្រាងរបស់តារាងសំណួរ។ "គុណភាព" មានន័យថាការផ្តល់ព័ត៌មានជាភស្តុតាងរាល់ចំលើយដែលបដិសេធ និងការអនុវត្តសំណួរស្ទង់មតិស្របតាមការយល់ដឹងពីវិធីសាស្ត្រនៃការដាក់ពិន្ទុ
- យោគយល់ និងចែករំលែកតាមរយៈការសន្ទនារវាងរដ្ឋាភិបាល និងសង្គមស៊ីវិល និងតួនាទីដែលរួមចំណែកដល់ការស្ទង់មតិ និងរបៀបវារៈនៃការងារកែទម្រង់ដើម្បីលើកកម្ពស់តម្លាភាព, ការចូលរួម និងគណនេយ្យភាពក្នុងកិច្ចដំណើរការថវិកា

## រចនាសម្ព័ន្ធនៃកម្រងសំណួរថវិកាបើកឆ្នាំ២០១៧

កម្រងសំណួរការស្ទង់ថវិកាបើកត្រូវបានបែងចែកចេញជា ០៥ ផ្នែកសំខាន់ៗ÷

**ផ្នែកទី០១÷** ប្រភពឯកសារថវិកាគន្លឹះអាចរកបានជាសាធារណៈ រួមមានផ្នែកសំណួរពាក់ព័ន្ធឯកសារថវិកាទាំង០៨។ សំណួរទាំងនេះបង្ហាញពីមូលដ្ឋាននៃការស្ទង់មតិទាំងមូល ត្បិតទម្រង់សំណួរផ្សេងៗផ្អែកលើសំណួរត្រូវបានសម្អាស។ សម្រាប់ឯកសារនីមួយៗ ប្រធានបទគ្របដណ្តប់រួមមាន÷

- ឆ្នាំសារពើពន្ធ ចំណងជើង
- លម្អិតពីភាពអាចរកបានប្រភពឯកសារ ÷ ថាតើការបោះផ្សាយរួចរាល់ឬនៅ? ផ្សព្វផ្សាយយឺត, ផ្សព្វផ្សាយតែផ្ទៃក្នុង និងអាចរកប្រភពឯកសារបាន ជាឯកសារទន់ ឬសំណៅដើម យោងលើសំណើសុំ
- កាលបរិច្ឆេទពេលឯកសារត្រូវបានបោះផ្សាយ ដោយអនុលោមភាពនឹងលក្ខណៈវិនិច្ឆ័យពេលវេលាការស្ទង់ថវិកាបើកជាដើម

**ផ្នែកទី០២÷** ប្រភពព័ត៌មានពាក់ព័ន្ធសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល (សំណួរទី១ ដល់ទី៥៣)

- ចំណូល ចំណាយ និងបំណុល
- ឆ្នាំថវិកា ឆ្នាំអាទិភាព និងការគ្រោងថវិកានៅឆ្នាំបន្តបន្ទាប់
- សក្តានុពលហានិភ័យ ជាឧទាហរណ៍ បំណុលឥតគ្រោងទុក និងបំណុលកកស្ទះ
- ព័ត៌មានបន្ថែមជាឧទាហរណ៍ស្ងួចនាករសមិទ្ធកម្ម និងវិធានការប្រឆាំងភាពក្រីក្រ

**ផ្នែកទី០៣÷** ភាពគ្រប់គ្រាន់នៃព័ត៌មានឯកសារថវិកាទាំង០៨ និងឯកសារគន្លឹះផ្សេងៗ (សំណួរទី៥៤ ដល់ទី១០២)

**ផ្នែកទី០៤÷** ភាពខ្លាំងរបស់ស្ថាប័នខាងក្រៅ (Oversight) (សំណួរទី១០៣

ដល់ទី១២៤)

- ស្ថាប័នសវនកម្មឯករាជ្យ
- ស្ថាប័ននីតិបញ្ញត្តិ
- អាជ្ញាធរសវនកម្មជាតិ

ផ្នែកទី០៥÷ ការចូលរួមរបស់សាធារណជនក្នុងកិច្ចដំណើរការថវិកា (សំណួរទី១២៥ ដល់ទី១៤២)

- ថវិកា÷ផ្នែករៀបចំ និងអនុវត្តថវិកា
- កិច្ចពិភាក្សាស្ថាប័ននីតិបញ្ញត្តិ និងការអនុម័តថវិកា
- សវនកម្ម ÷ ការចូលរួមក្នុងកំណត់កម្មវិធីសវនកម្ម និងការចូលរួមផ្នែកសវនកម្ម

## របៀបសម្គាល់ការឆ្លើយតបនឹងកម្រងសំណួរ ឬស្ទង់មតិទាំងអស់ (សន្ទស្សន៍ថវិកាបើក)

ប្រព័ន្ធ Indiba ជាប្រព័ន្ធវាយតម្លៃអនឡាញនូវកម្រិតពិន្ទុមធ្យមធម្មតាក្នុងចំណោមសំណួរទាំងអស់។ ព័ត៌មានគន្លឹះ រួមមាន÷ ការអង្កេត និងពណ៌នា, ទម្រង់ ២/៣ និង១/៣ (សមាមាត្រចំណូល/ចំណាយ) និងទម្រង់ ៣/២/១ (ឧទាហរណ៍ការដាក់លំដាប់ពិន្ទុ)។ ប្រព័ន្ធនៃការដាក់ពិន្ទុមានដូចតទៅ÷

- ជម្រើសសំណួរចំនួន០៥÷
  A)=១០០ B) =៦៧
  C) =៣៣ D)=០
  E)=N/A
- ជម្រើសសំណួរចំនួន ០៣÷
  A)=១០០ B) =០ C) = N/A
- សន្ទស្សន៍ថវិកាបើក (OBI) សំដៅដល់មធ្យមធម្មតានៃតម្លៃលេខឆ្លើយតបសំណួរនីមួយៗ
- ប្រសិនបើចំលើយទេឬ N/A លទ្ធផលសំណួរនឹងមិនត្រូវបានរាប់បញ្ចូលក្នុងពិន្ទុរបស់សន្ទស្សន៍ថវិកាបើកទេ។

## ការចូលរួម ភាពអាចរកបាននូវព័ត៌មាន និងពេលវេលាកំណត់ ដល់ការសម្រេចបានការស្ទង់មតិ និងសន្ទស្សន៍ថវិកាបើក

តាមពិតទៅ ការស្ទង់មតិ និងសន្ទស្សន៍ថវិកាបើកត្រូវបានចូលរួមដោយអង្គការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD), កិច្ចសហការចាប់ផ្តើមកំណែទម្រង់ថវិកាអាហ្វ្រិក (CABRI), មូលនិធិរូបិយវត្ថុអន្តរជាតិ, ក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA), បណ្តាញគ្រប់គ្រងចំណាយសាធារណៈប្រចាំអាស៊ី (PEMNA), ភ្នាក់ងាររដ្ឋាភិបាលបើក (OGP) និងការផ្តើមជាសកលសម្រាប់តម្លាភាពសារពើពន្ធ (GIFT)។ ដើម្បីទទួលយកនូវការស្ទង់មតិថវិកាបើកលុះត្រាតែរាល់ឯកសារទាំង ០៨ ត្រូវមានលក្ខណៈវិនិច្ឆ័យដូចតទៅ ÷

*ផលប្រយោជន៍ពីរយ៉ាង ÷ (ទី១) គឺជាឧបករណ៍ដ៏មានតម្លៃចូលរួមចំណែកក្នុងការសម្រេចបានគោលបំណងនៃគោលនយោបាយសាធារណៈ មិនមែនមានន័យថាតម្លាភាពថវិកាអាចជួយឱ្យសម្រេចបាននោះទេ, និង (ទី២) គឺធានាបានប្រសិទ្ធភាព, គណនេយ្យភាព និងបញ្ចៀសនូវអំពើពុករលួយក្នុងការគ្រប់គ្រងថវិកា។*

- ឯកសារថវិកាត្រូវបោះផ្សាយលើគេហទំព័ររបស់ស្ថាប័នរាជរដ្ឋាភិបាលដែលជាអ្នករៀបចំឯកសារនោះ
- ឯកសារថវិកាត្រូវតែអាចរកព័ត៌មានបានដោយឥតគិតថ្លៃ។

លើសពីនេះ ការឆ្លើយតបសំណួរនៃការអង្កេតនេះ ត្រូវបានគាំទ្រដោយអំណះអំណាងច្បាស់លាស់ ដូចជា ឯកសារយោងជាសាធារណៈ សេចក្តីថ្លែងការជាផ្លូវការរបស់រដ្ឋាភិបាល ឬអនុសាសន៍ដែលបានមកពីកិច្ចសម្ភាសមួយទល់មួយ ជាមួយមន្ត្រីរដ្ឋាភិបាល ឬភាគីដែលបានដឹងលឺផងទៀត។

ការអង្កេតនៃការផ្សព្វផ្សាយព័ត៌មានថវិកាត្រូវបានរៀបចំឡើងពីការបំពេញកម្រងសំណួរសម្រាប់ប្រទេសនីមួយៗ ដោយអ្នកជំនាញថវិកាឯករាជ្យ ដែលមិនជាប់ទាក់ទងនឹងរដ្ឋាភិបាលរបស់ប្រទេសនីមួយៗ។ បន្ទាប់ពីកម្រងសំណួររបស់ប្រទេសនីមួយៗត្រូវបានត្រួតពិនិត្យដោយឡែកៗពីគ្នាដោយអ្នកជំនាញអនាមិកមិនជាប់ទាក់ទងនឹងរដ្ឋាភិបាល។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានផ្តល់អនុសាសន៍ទៅលើសេចក្តីព្រាងលទ្ធផលនៃកម្រងសំណួរការអង្កេតនៃការផ្សព្វផ្សាយព័ត៌មានថវិកាផងដែរ។ គោលការណ៍ការស្ទង់មតិថវិកាបើកផ្អែកលើពេលវេលាជាក់លាក់ និងរាល់ឯកសារត្រូវផ្អែកលើឧត្តមានុវត្តអន្តរជាតិ។ តារាងខាងក្រោមនេះឆ្លុះបញ្ចាំងពីព័ត៌មានលម្អិតឯកសារថវិកាទាំង ០៨ ដល់សាធារណជន៕■

| លរ. | បរិយាយដំណាក់កាលនៅក្នុងវដ្តថវិកា | លក្ខណៈវិនិច្ឆ័យពេលវេលាត្រូវផ្សព្វផ្សាយជាសាធារណៈ (ឯកសារផ្អែកតាមឧត្តមានុវត្តន៍អន្តរជាតិ) | ត្រីមាសទី ១ ២០១៩ | ត្រីមាសទី ២ ២០១៩ | ត្រីមាសទី ៣ ២០១៩ | ត្រីមាសទី ៤ ២០១៩ |
|---|---|---|---|---|---|---|
| ០១ | រៀបចំថវិកា (របាយការណ៍បុរេថវិកា ឬយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨) សំណួរទី ១ ដល់ទី ៥៣ | ត្រូវតែផ្សព្វផ្សាយរយៈពេល ១ ខែមុនពេលសេចក្តីព្រាងច្បាប់ថវិកាត្រូវបានផ្ញើជូនអង្គនីតិបញ្ញត្តិដើម្បីពិចារណា | | | | |
| ០២ | រៀបចំថវិកា (សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល) សំណួរទី ៥៤ ដល់ ៥៨ | សំណើថវិការបស់ស្ថាប័ននីតិប្រតិបត្តិត្រូវតែផ្សព្វផ្សាយជូនដល់សាធារណៈខណៈពេលអង្គនីតិបញ្ញត្តិនៅតែកំពុងពិចារណាឬមុនពេលអង្គនីតិបញ្ញត្តិអនុម័តលើថវិកា | | | | |
| ០៣ | ការអនុម័តថវិកា (ថវិកាដែលបានអនុម័តយោងលើច្បាប់ថវិកា) សំណួរទី៥៨ ដល់៦៣ | ច្បាប់ថវិកាត្រូវផ្សព្វផ្សាយជូនសាធារណៈមិនឱ្យលើស ០៣ ខែ បន្ទាប់ពីច្បាប់នេះត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិ | | | | |
| ០៤ | គ្រប់ដំណាក់កាល (ថវិកាសម្រាប់ប្រជាពលរដ្ឋ) សំណួរទី ៦៤ ដល់ ៦៧ | ការបង្ហាញពាក្យសាមញ្ញមិនមានភាពបច្ចេកទេសអំពីថវិការដ្ឋត្រូវបានផ្សព្វផ្សាយតាមពេលវេលានៃឯកសារដែលបានយោង។ ឧទាហរណ៍ ថាតើឯកសារសម្រួលចេញពីច្បាប់ថវិកា (enacted budget) ត្រូវបានផ្សព្វផ្សាយមិនឱ្យលើសពី ០៣ ខែបន្ទាប់ពីច្បាប់ថវិកាត្រូវបានអនុម័ត | | | | |
| ០៥ | ការអនុវត្តថវិកា (របាយការណ៍ពាក់កណ្តាលឆ្នាំ) សំណួរទី ៦៨ ដល់ ៧៥ | របាយការណ៍ពាក់កណ្តាលឆ្នាំត្រូវផ្សព្វផ្សាយជូនសាធារណៈមិនឱ្យលើស ០៣ ខែ បន្ទាប់ពីរយៈពេលធ្វើរបាយការណ៍បញ្ចប់ | | | | |
| ០៦ | ការអនុវត្តថវិកា (របាយការណ៍ពាក់កណ្តាលឆ្នាំ) សំណួរ ៧៦ ដល់ ៨៣ | របាយការណ៍ពាក់កណ្តាលឆ្នាំត្រូវតែផ្សព្វផ្សាយជូនសាធារណៈមិនឱ្យលើស ៣ ខែ បន្ទាប់ពីរយៈពេលធ្វើរបាយការណ៍បញ្ចប់ | | | | |
| ០៧ | ការអនុវត្តថវិកា (របាយការណ៍ដំណាច់ឆ្នាំ) សំណួរ ៨៤ ដល់ ៩៦ | របាយការណ៍ដំណាច់ឆ្នាំត្រូវផ្សព្វផ្សាយជូនសាធារណៈមិនឱ្យលើស ០១ ឆ្នាំ បន្ទាប់ពីឆ្នាំសារពើពន្ធបញ្ចប់ | | | | |
| ០៨ | ការត្រួតពិនិត្យ (របាយការណ៍សវនកម្ម) សំណួរ ៩៧ ដល់ ១០២ | របាយការណ៍សវនកម្មត្រូវតែផ្សព្វផ្សាយដល់សាធារណៈមិនឱ្យលើសពី ១៨ ខែ | | | | |

# ឯកសារអង្គភាពថវិកាបើក (បច្ចុប្បន្នភាព ខែធ្នូ២០១៦)

*ប្រភព៖ International Budget Partnership Open Budgets. Transform Lives.*

| Key:<br>🟢 = Available to the Public Online<br>🟡 = Published Late, or Not Published Online, or Produced for Internal Use Only<br>🔴 = Not Produced | Pre-Budget Statement | Executive's Budget Proposal | Enacted Budget | Citizens Budget | In-Year Reports | Mid-Year Review | Year-End Report | Audit Report |
|---|---|---|---|---|---|---|---|---|
| Cambodia | 🟢 | 🟡 | 🟢 | 🟢 | 🟢 | 🟢 | 🟡 | 🟢 |
| Cameroon | 🟢 | 🟡 | 🟢 | 🔴 | 🟡 | 🟡 | 🟡 | 🟡 |
| Canada | 🔴 | 🟢 | 🟢 | 🔴 | 🟢 | 🟢 | 🟢 | 🟢 |
| Chad | 🟡 | 🟡 | 🟢 | 🟡 | 🟡 | 🟡 | 🟢 | 🟡 |
| Chile | 🔴 | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟢 |
| China | 🔴 | 🟡 | 🟢 | 🔴 | 🟢 | 🔴 | 🟢 | 🟢 |
| Colombia | 🟢 | 🟢 | 🟢 | 🟡 | 🟢 | 🟡 | 🟢 | 🟢 |
| Comoros | 🟡 | 🟡 | 🟢 | 🔴 | 🔴 | 🔴 | 🟢 | 🟡 |
| Costa Rica | 🔴 | 🟢 | 🟢 | 🟢 | 🟢 | 🔴 | 🟢 | 🟢 |
| Cote d'Ivoire | 🟡 | 🟢 | 🟢 | 🔴 | 🟢 | 🟡 | 🟢 | 🟢 |
| Croatia | 🟡 | 🟢 | 🟢 | 🟢 | 🟢 | 🔴 | 🟢 | 🟢 |
| Czech Republic | 🟢 | 🟢 | 🟢 | 🟡 | 🟢 | 🟡 | 🟢 | 🟢 |
| Democratic Republic of Congo | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🔴 | 🟡 | 🔴 |
| Dominican Republic | 🟡 | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟢 |
| Ecuador | 🟡 | 🟢 | 🟢 | 🟢 | 🟢 | 🟡 | 🟢 | 🔴 |
| Egypt | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟡 | 🟡 | 🟡 |
| El Salvador | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🔴 | 🟢 | 🟢 |
| Equatorial Guinea | 🟡 | 🟡 | 🟡 | 🔴 | 🔴 | 🟡 | 🟡 | 🟡 |
| Fiji | 🔴 | 🟢 | 🟢 | 🔴 | 🟡 | 🟡 | 🔴 | 🔴 |
| France | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟡 | 🟢 | 🟢 |
| Georgia | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟢 |
| Germany | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🔴 | 🟢 | 🟢 |
| Ghana | 🟡 | 🟢 | 🟢 | 🟢 | 🟡 | 🟢 | 🟢 | 🟢 |

# គណនេយ្យភាពវិស័យសាធារណៈ ៖ បទពិសោធន៍នៃចក្រភពអង់គ្លេស

## ចក្រភពអង់គ្លេស មានវិសាលភាពលើអង់គ្លេស (សភា), ស្កុតឡេន (សភា), ប្រទេសវេល (រដ្ឋសភា), និងប្រទេសអៀរឡង់ខាងជើង (រដ្ឋសភា) ដែលក្នុងនោះកិច្ចការមួយចំនួនត្រូវបានផ្តល់សិទ្ធិអំណាចពេញលេញដល់ប្រទេសទាំងនេះ រួមមាន វិស័យសុខាភិបាល, វិស័យសេវាសង្គម, វិស័យអប់រំ, វិស័យអភិវឌ្ឍន៍សេដ្ឋកិច្ច, វិស័យកសិកម្ម, វិស័យវប្បធម៌, វិស័យបរិស្ថាន, វិស័យសុវត្ថិភាពសាធារណៈ និងវិស័យដឹកជញ្ជូន។ រាជរដ្ឋាភិបាលនៃចក្រភពអង់គ្លេស ទទួលខុសត្រូវលើកិច្ចការគោលនយោបាយរួមមាន កិច្ចការបរទេស, ការពារជាតិ, សន្តិសុខសង្គម, គ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងពាណិជ្ជកម្ម។

ក្នុងវិស័យសាធារណៈនៃចក្រភពអង់គ្លេស បែងចែកជា ០៣ កម្រិត រួមមាន រដ្ឋាភិបាលថ្នាក់កណ្តាល (General Government), សាជីវកម្មសាធារណៈ (Public Corporations), និងរដ្ឋាភិបាលថ្នាក់ក្រោមជាតិ (Local Government)។ ចក្រភពអង់គ្លេស មាន ២៤ ក្រសួង (ហៅថា នាយកដ្ឋាន“Department”) ជារដ្ឋាភិបាលកណ្តាល ដែលមានអសនៈនៅសភា។ ដោយឡែក សម្រាប់រដ្ឋាភិបាលថ្នាក់ក្រោមជាតិមានរចនាសម្ព័ន្ធខុសៗគ្នារវាងប្រទេសអង់គ្លេស, ប្រទេសស្កុតឡេន, ប្រទេសវេល និងប្រទេសអៀរឡង់ខាងជើង ប៉ុន្តែរដ្ឋាភិបាលថ្នាក់កណ្តាលជាអ្នកផ្តល់ថវិកា និងត្រួតពិនិត្យ។ លើសពីនេះ រដ្ឋាភិបាលថ្នាក់ក្រោមជាតិមិនមានគណនេយ្យភាពផ្ទាល់ជាមួយនឹងសភាឡើយ។ ថវិកាចំណាយរបស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិមាន ០៣ ប្រភពចម្បងៗ ដូចជា ប្រភពពីរដ្ឋាភិបាលថ្នាក់កណ្តាល ប្រមាណ ៦១% ដែលក្នុងនោះ ៥៤% ត្រូវបានផ្ទេរផ្ទាល់សម្រាប់ចំណាយដូចជាកិច្ចដំណើរការសាលារៀន និងជួយប្រជាជនទន់ខ្សោយជាដើម,




ប្រភពពីពន្ធពាណិជ្ជកម្ម(ពន្ធលើអចលនទ្រព្យពាណិជ្ជកម្ម) ប្រមាណ ១៧%, និងប្រភពពីពន្ធលើអចលនទ្រព្យក្នុងស្រុក ប្រមាណ ២២%។ ក្នុងវិស័យសេវាហិរញ្ញវត្ថុសាធារណៈ មាននាយកដ្ឋានពីរដែលមានមុខងារ និងតួនាទីចម្បងក្នុងការគ្រប់គ្រងចំណូល និងចំណាយសាធារណៈ រួមមាន នាយកដ្ឋានចំណូល (សារពើពន្ធ) និង

អាករ (ក្រសួងចំណូល) និងនាយកដ្ឋានរតនាគារ (ក្រសួងហិរញ្ញវត្ថុ)។

*គ្រប់ក្រសួង/នាយកដ្ឋានដែលមានចំណូលមិនមែនសារពើពន្ធតម្រូវឱ្យរៀបចំនូវការព្យាករណ៍ចំណូលមិនមែនសារពើពន្ធ ជាមួយនឹងផែនការចំណាយ សម្រាប់រយៈពេល ៤ ឆ្នាំ និងផ្ញើទៅក្រសួង/នាយកដ្ឋានរតនាគារដើម្បីបូកសរុប ពិនិត្យ និងសម្រេចក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ដែលត្រូវឯកភាពសម្រាប់រយៈពេល ៤ ឆ្នាំ រីឯសភាអនុម័តលើកញ្ចប់ថវិកាប្រចាំឆ្នាំ*

នាយកដ្ឋានចំណូល និងអាករ មានតួនាទីក្នុងការគ្រប់គ្រងការប្រមូលចំណូលពន្ធផ្ទាល់, ពន្ធមូលធន, ពន្ធមិនផ្ទាល់, កាតព្វកិច្ចអាករ, ពន្ធទិដ្ឋាការដីធ្លី, និងពន្ធបរិស្ថាន។ ក្រៅពីនេះ នាយកដ្ឋានមានតួនាទីចូលរួមចំណែកក្នុងសេវាធានារ៉ាប់រងជាតិ, បែងចែងសម្រាប់អត្ថប្រយោជន៍កុមារ, និងការគាំទ្រផ្សេងៗទៀតដូចជាមូលនិធិកុមារ, ការទូទាត់ឥណទានពន្ធ, ការពង្រឹងបៀវត្សរ៍កម្រិតទាប, គ្រប់គ្រងការសម្អាតប្រាក់កខ្វក់របស់អាជីវកម្មពាក់ព័ន្ធប្រាក់ និងបោះផ្សាយទិន្នន័យអាជីវកម្មលើទំនិញជាដើម។ សម្រាប់ក្រសួង/នាយកដ្ឋានរតនាគារជាតិមានតួនាទីក្នុងការគ្រប់គ្រងចាត់ចែងលើ ÷

- **ថវិកាជាតិ ÷** ចំណាយរបស់គ្រប់ក្រសួង/នាយកដ្ឋាន, សេវាសាធារណៈ, ប្រាក់ឧបត្ថម្ភធន, គោលនយោបាយគ្រប់គ្រងសុខុមាលភាព និងចំណាយប្រចាំឆ្នាំ, និងវិនិយោគសាធារណៈ។
- **រៀបចំគោលនយោបាយសេវាសាធារណៈ÷** គោលនយោបាយសេវាហិរញ្ញវត្ថុ និងធនាគារ, ស្ថេរភាពហិរញ្ញវត្ថុ, និងធានាការប្រកួតប្រជែងរបស់ក្រុង។
- **ត្រួតពិនិត្យលើប្រព័ន្ធសារពើពន្ធ,**
- **ផ្តល់សេវាគម្រោងហេដ្ឋារចនាសម្ព័ន្ធ**
- **ធានាកំណើនសេដ្ឋកិច្ច** ព្រមទាំងមានគណនេយ្យភាពចំពោះសភាលើកិច្ចការងារនេះ។

សម្រាប់ការគ្រប់គ្រងចំណូល ក្រសួង/នាយកដ្ឋានរតនាគារមិនមានមុខងារក្នុងការប្រមូលចំណូលសារពើពន្ធឡើយ ដែលមុខងារនេះ គឺជាការទទួលខុសត្រូវរបស់ក្រសួង/នាយកដ្ឋានចំណូល និងរដ្ឋាករ ប៉ុន្តែមានសិទ្ធចាត់ចែងលើចំណូលមិនមែនសារពើពន្ធ។ ដោយឡែក គ្រប់ក្រសួង/នាយកដ្ឋានដែលមានចំណូលមិនមែនសារពើរពន្ធ តម្រូវឱ្យរៀបចំព្យាករណ៍ចំណូលមិនមែនសារពើពើន្ធ ជាមួយនឹងផែនការចំណាយសម្រាប់រយៈពេល ៤ ឆ្នាំ និងផ្ញើទៅក្រសួង/ នាយកដ្ឋានរតនគារ ដើម្បីបូកសរុប ពិនិត្យ និងសម្រេចក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ដែលត្រូវឯកភាពសម្រាប់រយៈពេល ៤ ឆ្នាំពេញ រីឯសភាអនុម័តលើកញ្ចប់ថវិកាប្រចាំឆ្នាំ។ ក្រសួង/នាយកដ្ឋានមានសិទ្ធិចាត់ចែងចំណូលមិនមែនសារពើពន្ធ(ឧទាហរណ៍ដូចជា ថ្លៃសេវាធ្វើដំណើរប្រើប្រាស់រថយន្តសាធារណៈ, សេវាទេសចរណ៍ជាដើម) ដែលប្រមូលបានសម្រាប់អនុវត្តចំណាយតាមមុខសញ្ញាដែលបានគ្រោងក្នុងផែនការ ហើយក្នុងករណីដែលមានអតិរេកពីការចាត់ចែងប្រើប្រាស់ ក្រសួង/នាយកដ្ឋាន ត្រូវផ្ទេរចំណែកលើសនេះទៅក្រសួង/នាយកដ្ឋានរតនាគារ ក្នុងគណនីរួម (Consolidated Fund) និងត្រូវបានកត់ត្រាជាចំណូលបន្ថែមផ្សេងៗដែលមានន័យថាក្រសួង/នាយកដ្ឋាន មិនមានសិទ្ធិក្នុងការរក្សាអតិរេកសាច់ប្រាក់ប្រតិបត្តិការចំណាយផ្សេងៗឡើយ លើកលែងទទួលបានការអនុម័តពីក្រសួង/ នាយកដ្ឋានរតនាគារ។

### ក្របខណ្ឌនៃការគ្រប់គ្រង និងការអនុវត្តចំណាយ

សភាបានផ្តល់សិទ្ធិអំណាចទៅឱ្យក្រសួង/នាយកដ្ឋានរតនាគារ ក្នុងការដឹកនាំរៀបចំគោលនយោបាយគ្រប់គ្រងចំណាយ និង

### គោលការណ៍ក្រមសីលធម៌សម្រាប់អង្គភាពសាធារណៈ

| | |
|---|---|
| ផលប្រយោជន៍រួម | ៖ បម្រើផលប្រយោជន៍សាធារណៈ |
| ភាពស្មោះត្រង់ | ៖ ចៀសវាងបម្រើផលប្រយោជន៍បុគ្គលដែលជះឥទ្ធិពលលើការងារ |
| សត្យានុម័ត | ៖ ត្រូវធ្វើការសម្រេចចិត្តដោយត្រឹមត្រូវ និងយុត្តិធម៌ដោយប្រើប្រាស់ភស្តុតាងជាក់លាក់ប្រកដដោយវិជ្ជាជីវៈខ្ពស់ |
| គណនេយ្យភាព | ៖ ទទួលខុសត្រូវចំពោះសាធារណៈជនសម្រាប់ការសម្រេចចិត្តនិងសកម្មភាព និងប្រឈមចំពោះការត្រួតវិនិច្ឆ័យ |
| បើកចំហ | ៖ ព័តមាន ឬការសម្រេចចិត្តត្រូវបានធ្វើដោយបើកចំហ និងមានតម្លាភាព |
| ភាពទុកចិត្ត | ៖ គួរទុកចិត្តបាន |
| ភាពជឿអ្នកដឹកនាំ | ៖ ផ្សព្វផ្សាយ និងលើកកម្ពស់គោលការណ៍នេះតាមជំនាញដឹកនាំ និងកែលម្អឥរិយាបទទន់ខ្សោយផ្សេងៗ |

ការអនុវត្តចំណាយដែលទទួលបានការអនុម័តពីសភាប្រចាំឆ្នាំ។ នាយកដ្ឋានរតនាគារធ្វើការវិភាជថវិកា និងអនុម័តថវិកាសម្រាប់រយៈពេល ៤ ឆ្នាំ សម្រាប់គ្រប់ក្រសួង/ នាយកដ្ឋាន ប៉ុន្តែថវិកាចំណាយប្រចាំឆ្នាំ (បច្ចេកស័ព្ទ ÷ Estimates) ត្រូវបានអនុម័តដោយសភា។ នាយកដ្ឋានរតនាគារផ្តល់សិទ្ធអំណាចក្នុងការអនុវត្តចំណាយតាមកម្មវិធីឬគម្រោងទៅដល់ក្រសួង/ នាយកដ្ឋានទាំងអស់។

### ការគ្រប់គ្រងថវិកាសាធារណៈ

គោលការណ៍គន្លឹះ ៥ ដែលត្រូវបានប្រើប្រាស់សម្រាប់ការគ្រប់គ្រងថវិកាសាធារណៈ រួមមាន ភាពទៀងទាត់, ភាពទាន់ពេលវេលា, ភាពសមស្រប, តម្លៃនៃលុយ, និងលទ្ធភាព។ ថវិកាសាធារណៈ ត្រូវបានព្យាករណ៍សម្រាប់រយៈពេល ៤ ឆ្នាំ និងត្រួតពិនិត្យ ៤ ឆ្នាំម្តង ដែលត្រូវពិនិត្យ និងសម្រេចត្រឹមគណៈរដ្ឋមន្ត្រី ដោយឡែកសម្រាប់ថវិកាប្រចាំឆ្នាំត្រូវយល់ព្រមដោយនាយកដ្ឋានរតនាគារ និងអនុម័តដោយសភា។ ថវិកាចំណាយសាធារណៈដែលបានគ្រោង ត្រូវធានាថាមានភាពទៀងទាត់ទាន់ពេលវេលា និងសមស្រប។ តម្រូវការការអនុម័តថវិកាពីនាយកដ្ឋានរតនាគារ។

### ការផ្តល់សិទ្ធិអំណាចដល់អង្គភាពអនុវត្ត (អង្គភាពថវិកា)

ក្រសួង/ នាយកដ្ឋានរតនាគារ ត្រូវ ÷

- ឯកភាពជាមួយក្រសួង/ ស្ថាប័នលើការសម្រេចក្នុងការអនុវត្តចំណាយ (ឧទាហរណ៍. លក្ខខណ្ឌវិនិច្ឆ័យ/ បច្ចេកទេសសម្រាប់វាយតម្លៃការវិនិយោគ, ការគ្រប់គ្រងគម្រោង ឬវាយតម្លៃក្រោយការអនុវត្ត)
- បង្កើតយន្តការដើម្បីត្រួតពិនិត្យគុណភាពនៃការសម្រេចចិត្តរបស់ក្រសួង / ស្ថាប័ន (ឧទាហរណ៍. ត្រួតពិនិត្យលើចំណាយដែលលើថវិកាអនុម័តប្រចាំឆ្នាំ, ផ្តល់សិទ្ធិអំណាចពេញលេញ ប៉ុន្តែទាមទារនូវកាលវិភាគដែលសកម្មភាពណាមួយត្រូវបានបំពេញពេញលេញ ហើយករណីមួយចំនួនអាចត្រូវបានយកមកត្រួតពិនិត្យ)
- លើកទឹកចិត្តដល់អង្គភាពអាណាប័កផ្ទេរសិទ្ធិក្នុងក្រសួង/ ស្ថាប័ននីមួយៗ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ ដូចជាមន្ត្រីគណនេយ្យអាចលើកយោបល់ថាតើគួរផ្តល់សិទ្ធិអំណាចទៅឱ្យអង្គភាពថវិកាដូចម្តេច។

### ករណីអង្គភាពអាណាប័កផ្ទេរសិទ្ធិមិនមានសិទ្ធ

- មុខសញ្ញាដែលមានភាពចម្រូងចម្រាស់
- មុខសញ្ញាដែលលើសថវិកាអនុម័ត
- ធានាចំណាយលើមុខសញ្ញាណាមួយដែលមិនទាន់ត្រូវបានកំណត់
- មុខសញ្ញាចំណាយដែលមានតម្លៃថ្លៃខ្ពស់
- មុខសញ្ញាចំណាយដែលត្រូវទាមទារជាចាំបាច់នូវការយល់ព្រមពីនាយកដ្ឋានរតនាគារ

### ការត្រួតពិនិត្យ

នាយកដ្ឋានរតនាគារជាតិកុងត្រូលើ ឬអគ្គសវនកម្មធ្វើការយ៉ាងជិតស្និទបំផុតក្នុងការចោទសួរទៅអង្គភាពថវិកា/ អាណាប័កផ្ទេរសិទ្ធិលើការអនុវត្តចំណាយលើករណីដូចជា÷

- គេចពីកាតព្វកិច្ចអនុវត្តច្បាប់ដែលចែងដោយនាយកដ្ឋានរតនាគារ
- បកស្រាយមិនសមស្រប ឬខុសឆ្ងាយពីគោលការណ៍ណែនាំនានារបស់នាយកដ្ឋានរតនាគារ
- មានបំណងព្យាយាម ឬឆ្លៀតឱកាសយកចំណេញលើស្ថានភាពនៃការផ្លាស់ប្តូរសិទ្ធិអំណាចឬការយល់ព្រមដោយផ្ទាល់ (មិនមានលាយលក្ខណ៍អក្សរ) របស់នាយកដ្ឋានរតនាគារ
- មានចេតនាអនុវត្តចំណាយទាំងឡាយណាដែលនាយកដ្ឋានរតនាគារមិនបានអនុម័តឬពិភាក្សា

*គោលការណ៍គន្លឹះ ៥ ដែលត្រូវបានប្រើប្រាស់សម្រាប់ការគ្រប់គ្រងថវិកាសាធារណៈ រួមមាន ភាពទៀងទាត់, ភាពទាន់ពេលវេលា, ភាពសមស្រប, តម្លៃនៃលុយ, និងលទ្ធភាព។*

### បញ្ហាប្រឈមនៃអភិបាលកិច្ចរបស់វិស័យសាធារណៈ

- កង្វះសមត្ថភាពក្នុងការប្រឈមនឹងបញ្ហារបស់មន្ត្រី
- កង្វះវគ្គបណ្តុះបណ្តាលជំហានបឋម (Induction training)
- មិនយល់ ឬទទួលស្គាល់អំពីសារៈសំខាន់នៃអនុលោមភាពក្នុងពេលអនុវត្តថវិកា
- កំសោយនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
- យុទ្ធសាស្ត្រដែលកំណត់ដោយថ្នាក់ដឹកនាំមិនមានប្រសិទ្ធភាព
- ភាពក្រអឺតក្រទមរបស់ថ្នាក់ដឹកនាំមួយចំនួន
- កង្វះយន្តការតាមដាន ឬមិនទទួលស្គាល់លើការផ្លាស់ប្តូរតម្រូវការសង្គម
- កង្វះការយល់ដឹងលើស្តង់ដារសីលធម៌សាធារណៈ និងសារៈសំខាន់នៃទស្សនៈទូទៅ (importance of perception)៕■

# ប្រព័ន្ធថវិកាប្រទេសម៉ាឡេស៊ី

ប្រទេសម៉ាឡេស៊ី ត្រូវបានចាត់ទុកជាប្រទេសដែលទទួលជោគជ័យក្នុងការកែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។ រដ្ឋបាលសហព័ន្ធម៉ាឡេស៊ី បានកំណត់យកទិសដៅនៃការអភិវឌ្ឍន៍ដោយដាក់ចេញនូវ "ចក្ខុវិស័យម៉ាឡេស៊ីឆ្នាំ ២០២០" (Malasia's vision 2020) ដោយប្រែក្លាយទៅជាប្រទេសចំណូលខ្ពស់។

ជាមួយនឹងឆន្ទៈសម្រេចបាននូវចក្ខុវិស័យនេះ រដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិជាបន្តបន្ទាប់ចំនួន ៤ រួមមាន៖

- គោលនយោបាយសេដ្ឋកិច្ចថ្មី (New Economic Policy 1971-1990)
- គោលនយោបាយអភិវឌ្ឍន៍ជាតិ (National Development Policy 1991-2000)
- គោលនយោបាយទស្សនវិស័យជាតិ (National Vision Policy 2001-2010)
- គោលនយោបាយកំណែទម្រង់ជាតិ គំរូសេដ្ឋកិច្ចថ្មី (National Transformation Policy - New Economic Model 2011-2020) ។

ដើម្បីគាំទ្រការអនុវត្តគោលនយោបាយរយៈពេលវែងខាងលើ រដ្ឋបាលសហព័ន្ធម៉ាឡេស៊ី បានចាប់ផ្តើមរៀបចំ និងអនុវត្តផែនការ ៥ ឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៥៦ រៀងមក។ នៅឆ្នាំ២០១៧ នេះ ម៉ាឡេស៊ីស្ថិតក្នុងដំណាក់កាលអនុវត្តផែនការ ៥ ឆ្នាំ ទី១១ (11th Malaysia Plan 2016-2020) ដែលរៀបចំដោយអង្គភាពផែនការសេដ្ឋកិច្ច (Economic Planning Unit-EPU) នៃទីស្តីការនាយករដ្ឋមន្ត្រី (Prime Minister's Department) និងមានការសហការជាមួយក្រសួងហិរញ្ញវត្ថុ។ ផែនការ ៥ ឆ្នាំ ត្រូវបានអនុម័តដោយសភាជាន់ខ្ពស់ និងជាមូលដ្ឋាននៃការរៀបចំថវិកាចរន្ត និងមូលធនប្រចាំឆ្នាំ។ ជាមួយនឹងការផ្លាស់ប្តូរគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររយៈពេលមធ្យម និងរយៈពេលវែង ប្រព័ន្ធថវិកាក៏បានធ្វើបច្ចុប្បន្នកម្ម និងផ្លាស់ប្តូរប្រព័ន្ធថវិកាផងដែរ។ ប្រព័ន្ធថវិការបស់ម៉ាឡេស៊ីមានការវិវត្តជា៤ដំណាក់កាល៖

- ដំណាក់កាលទី១ (១៩៥៧-១៩៦៨) ប្រព័ន្ធថវិកាប្រពៃណីផ្អែកលើធាតុចូលរួមមាន តម្រូវការចំណាយសម្រាប់បៀវត្ស ទឹក អគ្គិសនី សាំង សៀវភៅ បេសកកម្ម។ល។
- ដំណាក់កាលទី២ (១៩៦៩-១៩៩០) ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មកម្មវិធី (Program Performance Budgeting System-PPBS) ធាតុសំខាន់ៗរួមមាន ÷ កម្មវិធីគម្រោងចង្កោមសកម្មភាព សូចនាករសមិទ្ធកម្ម និងការត្រួតពិនិត្យ និងវាយតម្លៃ។ ទន្ទឹមនេះការចំណាយគឺត្រូវបានគ្រោងតាមកម្មវិធីនីមួយៗ ជាមួយនឹងលទ្ធផលជាក់លាក់តាមកម្មវិធីនីមួយៗផងដែរ រួមមាន ការកាត់បន្ថយភាពក្រីក្រ, មរណៈភាពកុមារជាដើម ។
- ដំណាក់កាលទី៣(១៩៩១-២០១២) ប្រព័ន្ធថវិកាកែតម្រូវ (Modified Budgeting System- MBS) ÷ តាមរយៈប្រព័ន្ធថវិកានេះ វិមជ្ឈការសិទ្ធអំណាច និងគណនេយ្យភាពពីក្រសួងហិរញ្ញវត្ថុដល់ក្រសួង-ស្ថាប័ន នឹងចាប់ផ្តើមគិតគូរការផ្សារភ្ជាប់គ្នារវាងធាតុចូល លទ្ធផល និងការជះឥទ្ធិពលជាវិជ្ជមាន ។
- ដំណាក់កាលទី៤(២០១៣-បច្ចុប្បន្ន) ប្រព័ន្ធថវិកាផ្អែកលើលទ្ធផលចុងក្រោយ (Outcome Based Budgeting-OBB)។ ប្រព័ន្ធនេះ ផ្តោតជាគន្លឹះលើការពង្រឹងការផ្សារភ្ជាប់អាទិភាពគោលនយោបាយជាតិទៅនឹងធនធាន ដោយប្រើឃ្នាស់នៃការផ្លាស់ប្តូរចំនួនប្រាំមួយ ដើម្បីធ្វើជាមគ្គុទ្ទេសក៏សម្រាប់ការរៀបចំប្រព័ន្ធថវិកាថ្មីដែលផ្តោតសំខាន់លើសមិទ្ធកម្ម, ការតម្រង់អាទិភាពតាមខ្សែឈររវាងអាទិភាពថ្នាក់ជាតិទៅនឹងសកម្មភាពរបស់ក្រសួង, ការគ្រប់គ្រងគំនិតផ្តួចផ្តើមឆ្លងវិស័យ, ការសម្របសម្រួលរវាង

## កំណែទម្រង់ថវិកានៃប្រទេសម៉ាឡេស៊ី




*ប្រភព៖ ក្រសួងហិរញ្ញវត្ថុ, ប្រទេសម៉ាឡេស៊ី*

ចំណាយមូលធន និងចំណាយចរន្ត, ការធ្វើប្រតិភូកម្មអំណាច ដោយភ្ជាប់នឹងគណនេយ្យភាពចំពោះលទ្ធផល និង ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ។

*រដ្ឋបាលសហព័ន្ធម៉ាឡេស៊ី បានកំណត់យកទិសដៅនៃការអភិវឌ្ឍ ដោយដាក់ចេញនូវ "ចក្ខុវិស័យម៉ាឡេស៊ីឆ្នាំ២០២០" ដោយប្រែក្លាយទៅជាប្រទេសចំណូលខ្ពស់។*

អ្នកគ្រប់គ្រងកម្មវិធីត្រូវបានតម្រូវឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងសមិទ្ធកម្ម ដែលក្នុងកិច្ចព្រមព្រៀងនោះមានចែងលម្អិតអំពីវិស័យដែលត្រូវអនុវត្ត, គោលដៅត្រូវសម្រេចបាន និងការវិភាជធនធាន។ គណនេយ្យភាពត្រូវបានកែលម្អច្រើននៅក្នុងដំណើរការរៀបចំបែបនេះ។ ទោះបីជាយ៉ាងនេះក្តី តម្លាភាពក្នុងដំណើរការរៀបចំថវិកា និងការប្រឹក្សាយោបល់ក្នុងចំណោមភាគីពាក់ព័ន្ធនៅមានការខ្វះខាត ដោយសារកត្តាពេលវេលា។

ជារួម ប្រទេសម៉ាឡេស៊ីទទួលបានជោគជ័យនៅក្នុងការអនុវត្តរៀបចំថវិកាសមិទ្ធកម្មធៀបនឹងប្រទេសនៅក្នុងតំបន់។ ស្រដៀងគ្នាទៅនឹងប្រទេសសមាជិកអង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច(Organization for Economic Co-operation and Development -OECD) និងប្រទេសថៃ, ការវិភាជថវិកា/ធនធានមិនអាស្រ័យទៅលើសូចនាករសមិទ្ធកម្ម (PIs) តែមួយមុខទេ ដោយក្នុងនោះកត្តាសេដ្ឋកិច្ច, នយោបាយ និងគោលនយោបាយផ្សេងៗទៀតត្រូវបានយកមកពិចារណាបន្ថែមមុនធ្វើការសម្រេចចិត្ត។ ក្នុងទិដ្ឋភាពនៃវិសហមជ្ឈការ និងវិមជ្ឈការ, ការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងប្រទេសម៉ាឡេស៊ី គឺមានលក្ខណៈមជ្ឈការខ្ពស់។ កម្មវិធីសំខាន់ផ្តោតលើវិស័យសុខភាព, ការអប់រំ, កសិកម្ម, អភិវឌ្ឍន៍ជនបទ, ហេដ្ឋារចនាសម្ព័ន្ធ, សន្តិសុខ និងពាណិជ្ជកម្មត្រូវបានអនុវត្តពីថ្នាក់កណ្តាល ដោយមានវត្តមាននាយកដ្ឋានថ្នាក់សហព័ន្ធនៅថ្នាក់ក្រោមជាតិ។


តើអ្វីជា
PEFA?




# ផ្នែកទី ៣ ៖ ទស្សនៈ និងមតិ

# ទស្សនៈថ្នាក់ដឹកនាំ




គ្មានលទ្ធផលណាដែលបានមកដោយមិនមានការបង់ថ្លៃនោះទេ ហើយក៏គ្មានកំណែទម្រង់ណាដែលសម្រេចបានដោយមិនមានការលះបង់នោះដែរ។ ហេតុនេះហើយទើបខ្ញុំតែងតែគូសបញ្ជាក់ជារឿយៗម្តងហើយម្តងទៀតថា

**"កែទម្រង់គឺរស់ មិនកែទម្រង់គឺស្លាប់"**។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ការអនុវត្តកម្មវិធីកែទម្រង់គឺប្រៀបបានទៅនឹងការ-ជួសជុលផ្ទះក្នុងខណៈដែលមានមនុស្សកំពុងតែរស់នៅក្នុងផ្ទះនោះ ទាមទារឱ្យមានការប្រយ័ត្នប្រយែងខ្ពស់បំផុត ដើម្បីកុំឱ្យប៉ះពាល់ដល់ការរស់នៅរបស់មនុស្សដែលនៅក្នុងនោះ។ យើងរៀនបណ្តើរ ធ្វើបណ្តើរ ពេលខ្លះត្រូវឈប់សញ្ជឹងគិត ពេលខ្លះត្រូវដើរយឺតៗ ពេលខ្លះត្រូវរត់។




**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# មតិដៃគូអភិវឌ្ឍន៍

យើងជឿជាក់ និងរំពឹងលើការកែលម្អចំណុចមួយចំនួនក្នុងដំណាក់កាលទី ៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ក្នុងនោះការពង្រឹងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុវត្តថវិកាកម្មវិធីពេញលេញដែលជាកត្តាសំខាន់ក្នុងការជំរុញការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការកែលម្អសេវាសាធារណៈ។




ឯកឧត្តម **George Edgar** ឯកអគ្គរដ្ឋទូត និជាប្រធាន សភាសហភាពអ៊ឺរ៉ុបនៅកម្ពុជា

មានភាពរីកចម្រើនច្រើន ចាប់តាំងពីរាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តនូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនាឆ្នាំ ២០០៤ កន្លងមក។ ក្នុងរយៈពេល ១២ ឆ្នាំកន្លងទៅនេះ រាជរដ្ឋាភិបាលបានអនុវត្តដំណាក់កាលទី ១ ឆ្ពោះទៅអនុវត្តដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បច្ចុប្បន្ន យើងឃើញមានការផ្លាស់ប្ដូរ និងកែលម្អមិនគួរឱ្យជឿដែលក្នុងនោះរួមមាន ថវិកាបានក្លាយទៅជាឧបករណ៍គោលនយោបាយកាន់តែអាចជឿទុកចិត្តបាន ព្រមទាំងការប្រមូលចំណូលមានការកើនឡើងគួរឱ្យកត់សម្គាល់។




លោកស្រី **Leah April** មន្ត្រីឯកទេសជាន់ខ្ពស់ វិស័យសាធារណៈ ជំនាញសកលផ្នែកអភិបាលកិច្ច ធនាគារពិភពលោក

## អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ
## ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**គណៈគ្រប់គ្រង**

- រស់ សីលវ៉ា — អគ្គលេខាធិការ នៃ **អ.គ.ហ.**
- បណ្ឌិត ហ៊ែល ចំរើន — អគ្គលេខាធិការរង នៃ **អ.គ.ហ.**
- មាស សុខសេនសាន — អគ្គលេខាធិការរង នៃ **អ.គ.ហ.**
- ប៉ែន ធីរុង្គ — អគ្គលេខាធិការរង នៃ **អ.គ.ហ.**
- ប៊ូ វង្សសុខា — អគ្គលេខាធិការរង នៃ **អ.គ.ហ.**
- យ៉េត វីណែល — អគ្គលេខាធិការរង នៃ **អ.គ.ហ.**
- អ៊ុង លុយណា — អគ្គលេខាធិការរង នៃ **អ.គ.ហ.**

**រៀបចំអត្ថបទដោយ**

- ផ្នែករដ្ឋបាលហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ
  - អ៊ុំ យុទ្ធី — ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ
  - អ៊ួច សោភ័ណ — មន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង
- ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព
  - សុគន្ធ ចរិយា — មន្ត្រីជំនាញជាន់ខ្ពស់
  - ឈុន ម៉ារឌី — មន្ត្រីជំនាញ
  - លី ពង្សរតនា — មន្ត្រីជំនាញ
- ផ្នែកគោលនយោបាយ និងរៀបចំថវិកា
  - អ៊ុង មករា — មន្ត្រីជំនាញ
  - ម៉េត រ៉ាម៉ន — ជំនួយការ
  - ផែង សុខម៉ៃ — ជំនួយការ

**នវានុវត្ត និងកែសម្រួលដោយ**

- ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព
  - សុគន្ធ ចរិយា — មន្ត្រីជំនាញជាន់ខ្ពស់
  - ឈុន ម៉ារឌី — មន្ត្រីជំនាញ
  - លី ពង្សរតនា — មន្ត្រីជំនាញ



## អាសយដ្ឋានទំនាក់ទំនង

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥) ២៣ ៤៣០ ៧៩១
ទូរសារ: (៨៥៥) ២៣ ៤៣០ ៧៤៥
admin@pfm.gov.kh
www.pfm.gov.kh
www.facebook.com/gscpfm